**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Science Economiques**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# កិច្ចសន្យាអាណត្តិ

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា. ពេក ជីវ៉ា**

**លោក. ស សុវណ្ណា**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក វុធ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទ ឈ្មោះ **ស សុវណ្ណា** និង នាងខ្ញុំឈ្មោះ **ពេក ជីវ៉ា** សូមគោរពថ្លែងអំណរគុណ **លោកឪពុក និងអ្នកម្ដាយ** ជាទីគោរព ដឹងគុណរបស់កូន ដែលលោកទាំងពីរមានគុណ ធំធេងបំផុត ពុំមានអ្វីមកប្រៀបផ្ទឹមបានឡើយ ចាប់តាំងពីកូនបានចាប់កំណើតក្នុងផ្ទៃអ្នកម្ដាយ រហូតបានប្រសូត្រមក លោកឪពុកអ្នកម្ដាយ តែងតែយកចិត្តទុកដាក់ ចិញ្ចឹមបីបាច់ ស្រលាញ់ថ្នាក់ថ្នម ប្រៀនប្រដៅធ្វើយ៉ាងណាបណ្ដុះផ្នត់គំនិតឲ្យកូនក្លាយជាកូនល្អ។ លុះកូនឈានដល់វ័យត្រូវសិក្សាលោកទាំងពីរមិនដែលរុញរា និងឲ្យកូនចូលរៀន ដោយចង់ឱ្យកូនមានចំណេះចេះដឹង។ បន្ទាប់ពីបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ទោះបីជាគ្រួសារមានជីវភាពមិនសូវធូរធា និងមិនល្អប្រសើរដូចគេយ៉ាងណាក្ដី ក៏លោកនៅតែផ្ដល់ឱកាស ជំរុញនិងលើកទឹកចិត្តជានិច្ច ព្រមទាំងឧបត្ថម្ភទាំងសម្ភារៈ ថវិការ ដើម្បីឲ្យកូនបានបន្តការសិក្សារដល់ថ្នាក់ឧត្តមរហូតមកដល់ពេលនេះ ដែលជារយៈពេលចុងក្រោយ ក្នុងការបញ្ចប់ការសិក្សារថ្នាក់បរិញ្ញាបត្ររបស់កូន។ កូនសូមគោរពអរគុណដល់អ្នកមានគុណទាំងពីរ ដែលផ្ដល់ឱកាស និងអ្វីៗ គ្រប់យ៉ាងដែលលោកបានផ្ដល់ឲ្យកូន ដោយមិនដែលហ៊ានពោលពាក្យថាហត់នឿយនោះឡើយ ក៏ដូចជា បងប្អូន តាយាយ មីងមា ដែលតែងតែគាំទ្រ ផ្ដល់ជាគំនិតយោបល់ជារៀងរហូតមក។

យើងខ្ញុំសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់គោរពជូន **ឯកឧត្តម លុយ ចណ្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយលោកយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងយ៉ាងម៉ត់ចត់ ធ្វើយ៉ាងណាឱ្យសាកលវិទ្យាល័យមួយនេះ មានការរីកចំរើន និងអភិវឌ្ឍន៍ ប្រកបដោយនិរន្តរ ភាព។ ហើយសូមគោពអរគុណដល់ **លោកគ្រូ អ្នកគ្រូ** ដែលជាសាស្ត្រាចារ្យ ដែលបានយកចិត្តទុកដាក់ ក្នុងការបង្រៀន ចែករំលែកនូវបទពិសោធន៍ និងដំបូន្មានល្អៗ ចាប់តាំងពីថ្នាក់ដំបូងនៃការសិក្សាថ្នាក់បរិញ្ញាបត្ររហូតដល់ថ្ងៃបញ្ចប់ នៃការសិក្សាឆ្នាំទី៤នេះផងដែរ។

ជាពិសេស សូមថ្លែងអំណរគុណដល់ **សាស្ត្រាចារ្យ ញឹក ឧត្ដី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការណែនាំ ដល់យើងខ្ញុំ ចំពោះការសរសេរសារណាបញ្ចប់ការសិក្សារថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្ររហូតទទួលបានជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំ សូមលើកហត្ថាប្រណម បួងសួង ដល់វត្ថុស័ក្ដសិទ្ធិ ទេព្តា ក្នុងលោកសូមប្រសិទ្ធិពរជ័យសួរស្ដីជូនចំពោះ **លោកឪពុក អ្នកម្ដាយ ឯកឧត្តម សាកលវិទ្យាធិការ សាស្ត្រាចារ្យ បងប្អូន ក៏ដូចជាមិត្តភក្តិ** សូមជួបប្រទះតែសេចក្ដីសុខសប្បាយ សុខភាពល្អ ជោគជ័យគ្រប់ភារកិច្ច ព្រមទាំងពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ** និង**ពលៈ** កុំបីឃ្លាងឃ្លៀតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រអស់រយៈពេលបួនឆ្នាំមកនេះ ឃើញថា មានទាំងភាពសប្បាយរីករាយ និងកើតទុក្ខបានលាយបញ្ចូលគ្នា ហើយជាពិសេសមានមុខវិជ្ជារៀនក៏ច្រើន ពីមួយឆ្នាំទៅមួយឆ្នាំ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏ពួកយើងសប្បាយរីករាយ និងទទួលយកដើម្បីទទួលបានចំណេះដឹងថ្មីៗ។ ក្នុងចំណោចមុខវិជ្ជាទាំងអស់ដែលកម្មវិធីសាលាបានដាក់ឱ្យពួកយើងធ្វើការសិស្សា គឺក្រុមយើងខ្ញុំពេញចិត្តទៅលើផ្នែករដ្ឋប្បវេណីជាខ្លាំង។

ដោយមើលឃើញថា នៅក្នុងសង្គមរស់នៅនាពេលបច្ចុប្បន្ន ការទំនាក់ទំនងរវាងបុគ្គលឯកជន និងបុគ្គលឯកជន ក៏ដូចជាក្រុមហ៊ុន មានសារៈសំខាន់ និងមានភាពចាំបាច់ ក្នុងការវិនិយោគ ក៏ដូចជាតម្រូវការក្នុងរស់នៅ។ យ៉ាងណាមិញ ការទំនាក់ទំនងទាំងនោះប្រាកដណាស់នឹងនាំឲ្យមាននូវចំណងទាក់ទងគតិយុត្តរវាងគូភាគី ហើយចាំបាច់ណាស់ក្នុងការតម្រូវឱ្យមានកិច្ចសន្យា។ នៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងផងដែរនូវប្រភេទនៃកិច្ចសន្យាមួយចំនួន ដែលមានការប្រើប្រាស់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា។ ក្នុងចំណោមកិច្ចសសន្យា ទាំងនោះ ពួកយើង មានការចាប់អារម្មណ៍ទៅលើកិច្ចសន្យាមួយគឺ **កិច្ចសន្យាអាណត្តិ**។

យើងខ្ញុំពិតជាមាន មោទនភាព និងសប្បាយរីករាយណាស់ ដែលបានតាក់តែងនៅស្នាដៃនេះឡើង ខណៈដែលពួកខ្ញុំមានការលំបាកក្នុងការស្រាវជ្រាវ ការខ្វះនូវឯកសារ ហើយជាពិសេសការស្វែងយល់របស់ ពួកខ្ញុំគឺនៅមានកម្រិត។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏ពួកខ្ញុំបានខិតខំរកឯកសារ និងធ្វើការស្វែងយល់អំពីប្រធានបទមួយនេះ រហូតដល់ពួកយើងទទួលបាននៅភាពជោកជ័យនៅសារណាមួយនេះ។ នៅក្នុងស្នាដៃនេះបានសរសេររៀបរាប់ការពីការប្រាស្រ័យទាក់ទងគ្នា ការបង្កើតកិច្ចសន្យា តួនាទី កាតព្វកិច្ច ការទទួលខុសត្រូវរបស់គូ ភាគី និងការបញ្ចប់ទៅវិញនៃកិច្ចសន្យា។ យើងខ្ញុំសង្ឃឹមថាស្នាដៃ នៃការសិក្សាស្រាវជ្រាវនូវសារណាមួយនេះ និងផ្តល់ជាឯកសារដែលមានអត្ថប្រយោជន៍ និងចូលរួមផ្តល់នៅចំណេះដឹងផ្នែកច្បាប់ទៅដល់ប្រជាពលរដ្ឋ សិស្សនិស្សិត និងអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ដើម្បីចូលរួមលើស្ទួយវិស័យយុត្តិធម៌ វិស័យឯកជនក៏ដូចជាវិស័យផ្សេងៗ និងជាពិសេសជួយឱ្យនីតិរដ្ឋនៅកម្ពុជាកាន់តែរីកចំរើន។

ទន្ទឹមនឹងនេះផងដែរ យើងខ្ញុំក៏សូមអភ័យទោសទុកជាមុននៅរាល់កំហុសខុសឆ្គងដែល កើតមានឡើងដោយអចេតនា ពីព្រោះថានៅក្នុងការសិក្សាស្រាវជ្រាវតែងតែ មានចំណុចខ្វះខាតមួយចំនួនជាក់ជាមិនខានគ្រាន់តែកំហុសមានតិច ឬច្រើនប៉ុណ្ណោះ ទាំងអក្ខរាវិរុទ្ធក្តី ទាំងពាក្យពេចន៍ និង ទាំងអត្ថន័យក្តី។ ដូច្នេះហើយ យើងខ្ញុំរង់ចាំជានិច្ចនៅ រាល់មតិរិះគន់ដើម្បីស្តាបនាដោយក្តីរីករាយពី សំណាក់លោកសាស្ត្រាចារ្យ ក៏ជាមិត្តអ្នកអានទាំងអស់ដែលនឹងកំពុងបានអាននូវសារណារបស់យើងខ្ញុំ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម**

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ២

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ២

**ជំពូកទី ១**

**ការបង្កើត និង លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាទូទៅ**

**ផ្នែកទី ១ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា** ........ ៤

**១.១. សំណើ** ........ ៤

១.១.១. សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ ........ ៤

១.១.១.១. ករណីគូភាគីអាចប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់មាត់ ........ ៤

១.១.១.២. ករណីគូភាគីទាក់ទងគ្នាដោយប្រយោល ឬតាមរយៈលិខិតអេឡិត្រូនិច ........ ៥

១.១.២. សំណើមានកំណត់អំឡុងពេលសម្រាប់ស្ទីការ ........ ៥

១.១.៣. ការដកសំណើ ........ ៥

១.១.៣.១. ការដកសំណើគ្មានកំណត់អំឡុងពេល ........ ៦

១.១.៣.២. ការដកសំណើមានកំណត់អំឡុងពេល ........ ៦

១.១.៤ អានុភាពនៃសំណើ ........ ៦

**១.២.ស្ទីការ** ........ ៧

១.២.១. ការមកដល់យឺតយ៉ាវនៃស្ទីការ ........ ៧

១.២.២. ស្ទីការដោយមានបន្ថែមការកែប្រែ ........ ៧

១.២.៣. អានុភាពនៃស្ទីការ ........ ៨

**១.៣. អញ្ញត្រកម្ម** ........ ៨

**ផ្នែកទី ២ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា** ........ ៩

**២.១. លក្ខខណ្ឌគ្រឹះ** ........ ៩

២.១.១. សមត្ថភាពគតិយុត្តទាក់ទងនឹងភាគី ........ ៩

២.១.១.១. សមត្ថភាពទទួលបាននូវសិទ្ធិ ........ ៩

២.១.១.២. សមត្ថភាពខាងឆន្ទៈ ........ ១០

២.១.១.៣. សមត្ថភាពក្នុងការធ្វើសកម្មភាព ........ ១១

២.១.២. មិនត្រូវមានវិការៈនៃការព្រមព្រៀង ........ ១១

២.១.២.១. ការភាន់ច្រឡំ ........ ១១

ក. ការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ........ ១១

ខ.ការភ័ន្តច្រឡំទៅលើចំណុចនៃកិច្ចសន្យាដែលគូភាគីយល់ឃើញថាសំខាន់ ........ ១២

គ. ការភាន់ច្រឡំដោយភាគីទាំងសងខាង ........ ១៣

ឃ. ការការពារតតិយជន ........ ១៣

២.១.២.២. ការឆបោក ........ ១៣

២.១.២.៣. ព័ត៌មានមិនពិត ........ ១៤

២.១.២.៤. ការរំលោភលើស្ថានភាព ........ ១៥

២.១.២.៥. ការគម្រាមកំហែង ........ ១៥

២.១.២.៦. ការកេងចំណេញហួសហេតុ ........ ១៦

២.១.២.៧. ឋបនីយផ្លូវចិត្ត ........ ១៦

២.១.៣. កម្មវត្ថុនៃកិច្ចសន្យា ឬលក្ខខណ្ឌមោឃៈភាពនៃកិច្ចសន្យា ........ ១៧

២.១.៣.១. បញ្ញត្តិស្ដីការអនុវត្តដោយបង្ខំ ........ ១៧

២.១.៣.២. សណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ ........ ១៨

២.១.៣.៣. ការបង្ហាញឆន្ទៈមិនពិត ........ ១៨

**២.២. លក្ខខ័ណ្ឌទម្រង់** ........ ១៩
២.២.១. លិខិតឯកជន ........ ១៩
២.២.២. លិខិតយថាភូត ........ ២០

## ជំពូកទី ២

## កិច្ចសន្យាអាណត្តិ

**ផ្នែកទី ១ ប្រភេទនៃកិច្ចសន្យាអាណត្តិ** ........ ២១
**១.១. និយមន័យ** ........ ២១
**១.២. លក្ខណៈទម្រង់នៃកិច្ចសន្យាអាណត្តិ** ........ ២២
**១.៣. កិច្ចសន្យាអាណត្តិដោយមិនយកកម្រៃ** ........ ២២
**១.៤. កិច្ចសន្យាអាណត្តិដោយយកកម្រៃ** ........ ២៣
**ផ្នែកទី ២ សិទ្ធិ និងភាតព្វកិច្ចរបស់អាណត្តិទាយក និង អាណត្តិគាហក** ........ ២៤
**២.១. សិទ្ធិ និងភាតព្វកិច្ចរបស់អាណត្តិទាយក** ........ ២៤
២.១.១. សិទ្ធិរបស់អាណត្តិទាយក ........ ២៤
២.១.២. កាតព្វកិច្ចរបស់អាណត្តិទាយក ........ ២៤
២.១.២.១. ករណីយកិច្ចបង់កម្រៃ ........ ២៤
២.១.២.២. ករណីកិច្ចបង់សោហ៊ុយជាមុន ........ ២៥
២.១.២.៣. ករណីយកិច្ចសងវិញនូវសោហ៊ុយដែលបានចំណាយ ........ ២៥
២.១.២.៤. ករណីយកិច្ចសងសំណងនៃការខូចខាត ........ ២៦
**២.២. សិទ្ធិ និងភាតព្វកិច្ចរបស់អាណត្តិគាហក** ........ ២៧
២.២.១. សិទ្ធិរបស់អាណត្តិគាហក ........ ២៧
២.២.១.១. សិទ្ធិទាមទារកម្រៃរបស់អាណត្តិគាហក ........ ២៧
ក. ករណីអាណត្តិយកកម្រៃ ........ ២៧
ខ. ករណីអាណត្តិដែលមិនយកកម្រៃ ........ ២៨
២.២.១.២.សិទ្ធិទាមទារឱ្យសងមកវិញនូវសោហ៊ុយដែលខ្លួនបានចំណាយ ........ ២៨
២.២.២. កាតព្វកិច្ច របស់អាណត្តិគាហក ........ ២៩

២.២.២.១. ករណីកិច្ចប្រុងប្រយ័ត្ន ....................................................................២៩
២.២.២.២. ករណីកិច្ចរាយការណ៍ ...................................................................... ៣០
២.២.២.៣. កាតព្វកិច្ចប្រគល់ ............................................................................ ៣០
២.២.២.៤. ការទទួលខុសត្រូវក្នុងការសងសំណងការខូចខាត
ដែលបានប្រើប្រាក់ ......................................................................... ៣១
២.២.២.៥. ករណីយកិច្ចសង្គ្រោះបន្ទាន់នៅក្រោយពេលបញ្ចប់អាណត្តិ......... ៣១

**ជំពូកទី ៣**

**ការបញ្ចប់ និងអានុភាពនៃការបញ្ចប់កិច្ចសន្យាអាណត្តិ**

**ផ្នែកទី ១ ការបញ្ចប់កិច្ចសន្យាអាណត្តិ**........................................................... ៣៣
**១.១. ការរំលាយកិច្ចសន្យាអាណត្តិ**...........................................................................៣៣
**១.២. ការបញ្ចប់ដោយមូលហេតុផ្សេងៗ**.................................................................. ៣៤
**ផ្នែកទី ២ អានុភាពនៃការបញ្ចប់កិច្ចសន្យា**...........................................................៣៦
**២.១. ពុំមានអានុភាពប្រតិសកម្ម**.............................................................................៣៦
**២.២. លក្ខខណ្ឌតតាំង** .............................................................................................. ៣៧
**សេចក្តីសន្និដ្ឋាន** ..........................................................................................................៣៨
**អនុសាសន៍** ................................................................................................................. ៤០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

មនុស្សគ្រប់រូបមិនអាចរស់នៅម្នាក់ឯងបានទេ គឺតែងតែមានទំនាក់ទំនងគ្នាជាញឹកញាប់ មិនថាទំនាក់ទំនងនៅក្នុងគ្រួសារ ឬនៅក្នុងកិច្ចការជំនួញទេ គឺតែងតែមានការពឹងពាក់គ្នាទៅវិញទៅមក ដែលនាំឱ្យបង្កើតនៅកិច្ចសន្យា ជៀសវាងការមានវិវាទ។ ការពឹងពាក់គ្នាឱ្យជួយធ្វើកិច្ចការអ្វីមួយដែលខ្លួនមិនអាចធ្វើបាន ឬដោយសារតែខ្លួនរវល់ពេកមិនអាចធ្វើកិច្ចការច្រើនក្នុងពេលតែមួយបាន ដូច្នេះក៏រកអ្នកផ្សេងដែលខ្លួនទុកចិត្តដើម្បីជួយធ្វើកិច្ចការឱ្យខ្លួន។ ការជ្រើសរើសបុគ្គលម្នាក់ឱ្យធ្វើកិច្ចការឱ្យខ្លួនគឺមានតាំងពីយូរណាមកហើយ រហូតមកដល់បច្ចុប្បន្ននេះ គឺកាន់តែមានច្រើនជាងពីមុនទៅទៀតដោយសារតែមានការអភិវឌ្ឍន៍ទៅមុខរហូត ហើយការងារក៏មានច្រើនទៀត។

ដោយសារតែមើលឃើញពីទំនាក់ទំនងគ្នាបែបនេះហើយទើប ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតឱ្យមានច្បាប់នៃកិច្ចសន្យាឡើង។ ចំពោះការបង្កើតឱ្យមានច្បាប់នេះឡើងគឺមិនមែនទើបតែមាននោះទេ គឺមានតាំងពីបុរាណមកម្ល៉េះ គឺគ្រាន់តែមិនមានចែងជាលាយលក្ខណ៍អក្សរ ឱ្យច្បាស់លាស់តែប៉ុណ្ណោះ រហូតមកដល់ឆ្នាំ ១៩៦៧ ទើបប្រទេសកម្ពុជាមានច្បាប់កិច្ចសន្យាមួយជាក់លាក់ដែលចែងនៅក្នុងក្រមរដ្ឋប្បវេណី ហើយដែលមានចែងពី កិច្ចសន្យាសហគ្រាស កិច្ចសន្យាជួល កិច្ចសន្យាធានា និងកិច្ចសន្យាផ្សេងៗទៀត ហើយក្នុងនោះដែរក៏មានចែងពីកិច្ចសន្យាអាណត្តិដែរ ដែលជាកិច្ចសន្យាដែលត្រូវលើកមកធ្វើការស្រាវជ្រាវ។ នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ១៩៦៧ បានឱ្យនិយមន័យ អាណត្តិ ថាគឺជាកិច្ចសន្យា ដែលជនម្នាក់ឱ្យអំណាចទៅ ជនម្នាក់ទៀត ឱ្យយកទៅបំពេញកិច្ចការខ្លះ ខាងតុលាការក្នុងនាមខ្លួន និងតាងនាមខ្លួន[1]។ ប៉ុន្តែឃ្លាថា «ក្នុងនាមខ្លួន» និង «តាងខ្លួន» ដែលប្រើក្នុងមាត្រា ១២៦៨ នេះត្រូវបានលុបចោល។ មូលហេតុដោយសារតែមានការទិតៀនពីអ្នកច្បាប់កម្ពុជាថា មិនដឹងជាឃ្លានេះចង់សំដៅទៅលើអ្នកណាឱ្យប្រាកដ។ លើសពីនេះទៅទៀត មាត្រានេះមិនបានបញ្ជាក់ឱ្យច្បាស់លាស់អំពីទម្រង់នៃសកម្មភាពរបស់អាណត្តិគាហកថា តើធ្វើក្នុងនាមអាណត្តិគាហក ឬ ក្នុងនាមអាណត្តិទាយកនោះទេ។ ក្រោយមកក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានបង្កើតឡើង ដែលបានបញ្ញត្តិពីកិច្ចសន្យាអាណត្តិនិងបានឱ្យនិយមន័យផ្សេងពីនេះ និងច្បាស់លាស់ទៀតផង។

អាណត្តិ សំដៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អាណត្តិទាយក ប្រគល់សិទ្ធិអំណាចឱ្យភាគីម្ខាងទៀត ហៅថា អាណត្តិគាហកធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក[2]។ មានន័យថា ជាការប្រគល់សិទ្ធិអំណាចរបស់អាណត្តិទាយក ទៅឱ្យបុគ្គលម្នាក់ទៀត ដែលនៅក្នុងក្រមរដ្ឋប្បវេណីឱ្យឈ្មោះថា អាណត្តិ

[1] មាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ១៩៦៧

[2] មាត្រា ៦៣៧ នៃក្រមរដ្ឋប្បវេណី នៃព្រះជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

គាហក ដើម្បីធ្វើនូវកិច្ចការទាំងឡាយក្នុងនាមអាណត្តិទាយក។ ចំពោះអត្ថន័យ នៃកិច្ចសន្យាយើងនឹងធ្វើការសិក្សានៅផ្នែកខាងមុខ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តើកិច្ចសន្យាអាណត្តិ មានន័យយ៉ាងដូចម្តេច? តើនីតិវិធីនៃការបង្កើតកិច្ចសន្យាអាណត្តិ ដូចគ្នាទៅនឹងការបង្កើតកិច្ចសន្យាផ្សេងៗទៀត ឬក៏អត់? តើសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យាមានអ្វីខ្លះ? តើការបង្កើតកិច្ចសន្យានេះឡើង មានសារៈសំខាន់អ្វីខ្លះដល់គូភាគី?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការជ្រើសរើសប្រធានបទនេះ គឺចង់ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីទំហំនៃសិទ្ធិ និងការអនុវត្តកាព្វកិច្ចរបស់គូភាគី ជាពិសេសគឺអាណត្តិគាហក លើសពីនេះគឺពួកយើងចង់ញែកឱ្យបានច្បាស់ រវាងកិច្ចសន្យាអាណត្តិ និងការតំណាង។ ប៉ុន្តែក៏សូមអធ្យាស្រ័យ ដោយសារតែពួកយើងធ្វើការសិក្សាតែទៅលើតែកិច្ចសន្យាអាណត្តិតែមួយទេ ហើយក៏មិនបានធ្វើការប្រៀបធៀបរវាងកិច្ចសន្យាទាំងពីរនេះដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនេះ គឺទាក់ទងនឹងរឿងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងកិច្ចសន្យាអាណត្តិ ដែលមានចែងនូវក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ជាធរមាន ដូច្នេះ យើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវតែទៅលើច្បាប់សាជាតុតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវ គឺចង់ឱ្យអ្នកសិក្សានៅគ្រប់មជ្ឈដ្ឋានបានសិក្សាស្វែងយល់ពីកិច្ចសន្យាមួយនេះ និងដើម្បីទុកជាឯកសារសម្រាប់អ្នកជំនាន់ក្រោយក្នុងការស្វែងយល់ និងជាពិសេសធ្វើឱ្យយើងដែលជាអ្នកតាក់តែងនូវសារណានេះឡើងកាន់តែយល់ច្បាស់នៅកិច្ចសន្យាមួយនេះ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទ "**កិច្ចសន្យាអាណត្តិ**" យើងនឹងធ្វើការសិក្សាទៅលើ បី ជំពូកគឺ៖

ជំពូកទី ១ ការបង្កើត និងល័ក្ខខ័ណ្ឌសុពលភាពនៃកិច្ចសន្យាទូទៅ

ជំពូកទី ២ កិច្ចសន្យាអាណត្តិ

ជំពូកទី ៣ ការបញ្ចប់ និងអានុភាពនៃការបញ្ចប់កិច្ចសន្យាអាណត្តិ ។

ដូច្នេះយើងនឹងធ្វើការសិក្សា បីជំពូកនេះដែលមាននៅក្នុងទំព័រខាងមុខបន្តបន្ទាប់ទៀត។

# ជំពូកទី ១
# ការបង្កើត និង លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាទូទៅ

នៅក្នុងការរស់នៅប្រចាំថ្ងៃ ការទំនាក់ទំនង គឺជារឿងចាំបាច់ដែលពុំអាចខ្វះបាន យ៉ាងណាមិញ ដើម្បីឲ្យការទំនាក់ទំនងនោះ មានភាពរឹងមាំនៅក្នុងរបបគតិយុត្តិ គឺត្រូវតែមានការបង្កើតឡើងនូវកិច្ចសន្យា។ កិច្ចសន្យាមានច្រើនប្រភេទ ដែលនឹងត្រូវបានប្រើប្រាស់ អាស្រ័យទៅតាមប្រភេទ នៃកម្មវត្ថុ និងស្ថានភាពជាក់ស្តែង។ ដោយឡែក កិច្ចសន្យាអាណត្តិក៏ជាប្រភេទកិច្ចសន្យាមួយចាំបាច់ដែរ ដែលតែងតែឃើញគេយកទៅប្រើប្រាស់ជាញឹកញាប់មិនថានៅក្នុងវិស័យតុលាការ ឬវិស័យឯកជននោះទេ។ ដើម្បីឲ្យកាន់តែច្បាស់ យើងខ្ញុំសូមធ្វើការលើកយកនៅនិយមន័យ នៃពាក្យគន្លឹះមួយចំនួនទាក់ទងទៅនឹងប្រធានបទនេះ៖

**កិច្ចសន្យា** គឺជាកិរិយា ដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច[3]។

**អាណត្តិ** យោងទៅតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត សំដៅលើពាក្យបង្គាប់ ឧបង្គាប់។ សារលិខិតណាមួយ ដែលបុគ្គលណាមួយប្រគល់សិទ្ធិ របស់ខ្លួនទៅឲ្យអ្នកដទៃ ដើម្បីធ្វើកិច្ចការ ក្នុងនាមរបស់ខ្លួន។

ចំណែកពាក្យ **អាណត្តិ** ក្នុងន័យច្បាប់ សំដៅទៅលើកិច្ចសន្យាមួយដែល ភាគីម្ខាង ហៅថា អាណត្តិទាយក ប្រគល់សិទ្ធិអំណាច ឲ្យភាគីម្ខាងទៀត ហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បី អាណត្តិទាយក[4]។

ដូចនេះ កិច្ចសន្យាអាណត្តិ មានន័យថា ជាសកម្មភាពដែលគូភាគី មានឆន្ទៈត្រូវគ្នា ដែលភាគីម្ខាងជាណត្តិទាយក ប្រគល់សិទ្ធិអំណាចរបស់ខ្លួន ទៅឲ្យភាគីម្ខាងទៀតជាអាណត្តិគាហក ដើម្បីធ្វើការចាត់ចែង កិច្ចការឱ្យខ្លួន។

ពាក្យថា **កិច្ចការ** នៅក្នុងអាណត្តិ រាប់បញ្ចូលគ្រប់កិច្ចការដូចជា ការធ្វើកិច្ចសន្យា អន្តរការីនៃអចលនវត្ថុ សិទ្ធិក្នុងការធ្វើបណ្តឹង ជាអាទិ៍។ ឧទាហរណ៍៖ **ក** ផ្តល់សិទ្ធិតំណាងឱ្យ **ខ** ទៅចុះកិច្ចសន្យាទិញរថយន្ត ជាមួយ **គ** ។ នេះគឺជាឧទាហរណ៍ នៃការបង្កើតកិច្ចសន្យាអាណត្តិ។ ទន្ទឹមនឹងនេះ ប្រសិនបើ **ក** ស្នើសុំឱ្យ **ខ** ស្វែងរកអ្នកទិញដីរបស់ **ក** ហើយ **ខ** បានធ្វើជាឈ្មួញកណ្តាល រវាង **ក** និងអ្នកទិញ **គ**។ នេះគឺជាឧទាហរណ៍នៃអន្តរការី នៃអចលនវត្ថុ។ ប៉ុន្តែ ការរក្សាទុកវត្ថុ មិនរាប់បញ្ចូលទៅក្នុងកិច្ចការ នៅក្នុងអាណត្តិទេ គឺស្ថិតនៅក្នុងកិច្ចការបញ្ញើ។

---

[3] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[4] មាត្រា ៦៣៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ក្រោយពីបានសិក្សាស្វែងយល់អំពីអត្ថន័យ ដោយសង្ខេបអំពី កិច្ចសន្យាអាណត្តិ នឹងដើម្បីឱ្យកាន់តែច្បាស់ពីកិច្ចសន្យាអាណត្តិ យើងនឹងធ្វើការស្វែងយល់ ពីលក្ខខណ្ឌអានុភាពនៃការបង្កើតកិច្ចសន្យាអាណត្តិ (ផ្នែកទី ១) និងលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាអាណត្តិ (ផ្នែកទី ២)។

## ផ្នែកទី ១ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា

ជាគោលការណ៍ កិច្ចសន្យាបានបង្កើតឡើងនៅពេលដែលមាន សំណើ និងស្វីការត្រូវគ្នា។ សំណើ និងស្វីការត្រូវគ្នាជាហេតុផលដែលនាំឲ្យកិច្ចសន្យានោះមានអានុភាព ចងនូវសិទ្ធិ និងករណីយកិច្ចរបស់ភាគី នៃកិច្ច-សន្យា។ ទោះបីជា សំណើ និងស្វីការត្រូវគ្នាក៏ដោយ ករណីខ្លះអានុភាពនៃកិច្ចសន្យាមិនត្រូវបានកើតឡើងឡើយ ដោយហេតុថា កិច្ចសន្យានោះមានវិការៈ ដូចជា៖ ការបង្ហាញឆន្ទៈដែលមានវិការៈ ឬភាគីនៃកិច្ចសន្យា ជាជនត្រូវបានកម្រិតសមត្ថភាព បានបង្ហាញឆន្ទៈលុបចោលកិច្ចសន្យា ឬខ្លឹមសារនៃកិច្ចសន្យានោះផ្ទុយនូវអ្វីដែល ក្រមរដ្ឋប្បវេណីបានហាមឃាត់។

### ១.១ សំណើ

សំណើ គឺជាការស្នើសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនិង ចំណងគតិ-យុត្ត ក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនោះ។ មានន័យថា សំណើ គឺជាការបង្ហាញឆន្ទៈរបស់ភាគីម្ខាង ក្នុងគោលបំណងចងបង្កើតនូវកិច្ចសន្យាជាមួយនឹងភាគី ម្ខាងទៀត ហើយសិទ្ធិ និងករណីយកិច្ចនឹងកើតមានឡើង នៅពេលដែលភាគីម្ខាងបានបង្ហាញឆន្ទៈ យល់ព្រមចំពោះសំណើនោះ។ ដើម្បីកំណត់បានថា តើសកម្មភាពណាមួយត្រូវបានសន្មត់ថាជា សំណើ នោះវាអាស្រ័យទៅលើសកម្មភាពរស់នៅរបស់មនុស្សនៅក្នុងសង្គម។ សកម្មភាពទាំងអស់នោះ អាចស្តែងចេញតាមរយៈជាសំណេរ ពាក្យសំដី ឬ កាយវិការ ជាអាទិ៍។

#### ១.១.១. សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ

សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ គឺជាសំណើមួយដែលភាគីអ្នកស្នើបានដាក់សំណើរបស់ខ្លួន ទៅភាគីម្ខាងទៀតដោយមិនបានបញ្ជាក់អំពីអំឡុងពេលសម្រាប់ធ្វើស្វីការនៅពេលណាមួយជាក់លាក់ ដូចជា ករណីដែលគូភាគីមិនបានប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់ និងការទាក់ទងគ្នាដោយប្រយោល។

##### ១.១.១.១. ករណីគូភាគីអាចប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់មាត់

ចំពោះសំណើដែលគ្មានកំណត់អំឡុងពេល ប្រសិនបើស្ថិតនៅក្នុងស្ថានភាពណាមួយ ដែលគូភាគីទាំងសងខាងកំពុងនិយាយគ្នា ហើយសំណើនោះអាចនឹងឆ្លើយតបភ្លាមៗ ផ្ទុយទៅវិញ ភាគីដែល ទទួលសំណើមិនបានបង្ហាញឆន្ទៈយល់ព្រមភ្លាមៗទេ នាំឲ្យសំណើនោះនឹងត្រូវបាត់បង់អានុភាព។

ឧទាហរណ៍៖ ក្នុងករណីដែលកំពុងនិយាយតទល់គ្នា ភាគី **ក** បានដាក់សំណើទិញម៉ូតូពីភាគី **ខ** ក្នុងតម្លៃ ១៧០០ ដុល្លារ តែភាគី **ខ** មិនបានបង្ហាញឆន្ទៈអ្វីឡើយ ពោលគឺភាគី **ខ** នៅស្ងៀម នៅក្នុងករណីបែបនេះ សំណើទិញម៉ូតូ ក្នុងតម្លៃ ១៧០០ដុល្លារ និងត្រូវបានបាត់បង់អានុភាព។

**១.១.១.២. ករណីគូភាគីទាក់ទងគ្នាដោយប្រយោល ឬតាមរយៈលិខិតអេឡិចត្រូនិច**

ករណីសំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ ហើយគូភាគីមិនបាននិយាយគ្នា ដូចជា៖ ការសរសេរសំបុត្រ ឬការផ្ញើសារតាមប្រព័ន្ធអ៊ីនធឺណេតជាអាទិ៍ អ្នកស្នើមិនអាចដកសំណើ វិញក្នុងអំឡុងពេលសមរម្យបានឡើយ។ ពាក្យថា **"អំឡុងពេលសមរម្យ"** មិនត្រូវបានផ្តល់និយមន័យ ច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណីទេ។ ដូច្នេះហើយពាក្យថា "អំឡុងពេលសមរម្យ" គឺ អាស្រ័យទៅលើការបកស្រាយដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃប្រភេទកិច្ចសន្យានីមួយៗ។

**១.១.២. សំណើមានកំណត់អំឡុងពេលសម្រាប់ស្វីការ**

ភាគីអ្នកស្នើអាចធ្វើការដាក់សំណើដល់ភាគីម្ខាងទៀត ក្នុងការផ្តល់ស្វីការដោយមានកំណត់អំឡុងពេលសម្រាប់ស្វីការ។ ក្នុងករណីដែលភាគីម្ខាង មិនព្រមឆ្លើយតបនឹងសំណើក្នុងអំឡុងពេលមានកំណត់សម្រាប់ស្វីការ សំណើនោះនឹងបាត់បង់សុពលភាព បន្ទាប់ពីការផុតអំឡុងពេលសម្រាប់ផ្តល់ស្វីការ។ ក្នុងករណីសំណើមិនបានបញ្ជាក់ពីពេលវេលាច្បាស់លាស់ នៃការចាប់ផ្តើមទេ អំឡុងពេលសម្រាប់ស្វីការត្រូវគិតចាប់ពីថ្ងៃជូនដំណឹង[5]។

ឧទាហរណ៍៖ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩ ភាគី **ក** បានដាក់សំណើលក់ដីមួយកន្លែងតម្លៃ ២០០០០០ដុល្លារ ទៅភាគី **ខ** ដោយធ្វើការកំណត់ថាភាគី **ខ** អាចធ្វើការផ្តល់ស្វីការចាប់ពីថ្ងៃដែលបានដាក់សំណើរហូតដល់ថ្ងៃ១ ខែកក្កដា ឆ្នាំ២០១៩។ ដូច្នេះ សំណើនឹងមានសុពលភាពដោយគិតចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ សំណើនឹងអស់សុពលភាពចាប់ ពីថ្ងៃទី២ ខែកក្កដា ឆ្នាំ ២០១៩។

**១.១.៣. ការដកសំណើ**

ការដកសំណើ គឺជាការបង្ហាញឆន្ទៈរបស់ភាគីម្ខាងទៅភាគីម្ខាងទៀត ចំពោះការលុបចោលនូវសំណើរបស់ខ្លួន។ ការដកសំណើត្រូវបានបែងចែកជាពីរប្រភេទ រួមមាន ការដកសំណើដែលគ្មានកំណត់អំឡុងពេល និងមានកំណត់អំឡុងពេល។

[5] មាត្រា ៣៣៨ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**១.១.៣.១. ការដកសំណើគ្មានកំណត់អំឡុងពេល**

ដូចដែលបានបកស្រាយរួចមកហើយ នៅខាងលើនេះសំណើដែលគ្មានកំណត់អំឡុងពេល សម្រាប់ស្ទីការ អាចជាសំណើដែលស្ថិតនៅក្នុងស្ថានភាពចរចារគ្នាដោយផ្ទាល់ ឬមិនផ្ទាល់។ ចំពោះសំណើដែលកំពុងនិយាយគ្នា ត្រូវបាត់បង់អានុភាព នៅពេលដែលភាគីទទួលសំណើមិនបាន បង្ហាញឆន្ទៈយល់ព្រមភ្លាមៗ ចំពោះភាគីអ្នកស្នើ។

ដោយឡែក ចំពោះសំណើដែលបានធ្វើឡើងដោយគូភាគីតាមរយៈចម្ងាយ ឬមិនផ្ទាល់ សំណើនឹងមិនត្រូវបានបាត់បង់អានុភាពដោយការហួសនូវអំឡុងពេលសមរម្យឡើយ ពោលគឺសំណើនឹងត្រូវបាត់បង់អានុភាពតាមរយៈការដកសំណើរបស់អ្នកស្នើ បានន័យថា អ្នកស្នើអាចធ្វើការដកសំណើ របស់ខ្លួនបានតាមរយៈ ការជូនដំណឹងអំពីការដកសំណើទៅភាគីដែលទទួលសំណើ ក្រោយពីពេល ដែលអំឡុងពេលសមរម្យត្រូវបានកន្លងផុត។ ការដកសំណើនឹងមានអានុភាព លុះត្រាតែ ការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលដែលភាគីម្ខាងទៀតបានជូន ដំណឹងអំពីស្ទីការ[6]។

**១.១.៣.២. ការដកសំណើមានកំណត់អំឡុងពេល**

ការដកសំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្ទីការ ភាគីអ្នកស្នើមិនអាចធ្វើការដក សំណើរបស់ខ្លួនមកវិញបានទេនៅក្នុងអំឡុងពេលនោះ ពីព្រោះគោលបំណងនៃសំណើ គឺដើម្បី បញ្ជាក់អំពីឆន្ទៈរបស់អ្នកស្នើក្នុងការរង់ចាំស្ទីការរបស់ភាគីម្ខាងទៀត។ ម្យ៉ាងវិញទៀត សំណើនឹង ត្រូវបាត់បង់អានុភាព នៅពេលដែលអ្នកស្នើបានដឹងអំពីការបដិសេធនៃសំណើ នៅក្នុងអំឡុងពេល សម្រាប់ស្ទីការនោះ ឬករណីដែលអំឡុងពេលសម្រាប់ស្ទីការត្រូវបានកន្លងផុត។

**១.១.៤ អានុភាពនៃសំណើ**

តើអានុភាពនៃសំណើត្រូវបានបង្កើតឡើងនៅពេលណា? អនុលោមទៅតាមគោលការណ៍ នៃការបង្ហាញឆន្ទៈ សំណើត្រូវបានបង្កើតអានុភាព នៅពេលដែលសំណើនោះបានទៅដល់ភាគីម្ខាងទៀត នៃកិច្ចសន្យា[7]។ ករណីនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ មុនពេលដែលសំណើបានទៅដល់ភាគីទទួលសំណើ ទោះបីជាអ្នកធ្វើសំណើបានទទួលមរណភាពក៏ដោយ ឱ្យតែសំណើទៅដល់ភាគីទទួលសំណើ នោះនាំឱ្យអានុភាពនៃសំណើនឹងកើតមានឡើង។ ពាក្យថា " បានដល់ " មានន័យថា វាមិនចាំបាច់ទាល់តែអ្នកទទួលសំណើ បានទទួលសំណើដោយផ្ទាល់ ឬបានអានសំណើនោះទេ។

[6] មាត្រា ៣៣៩ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[7] មាត្រា ៣៣៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឧទាហរណ៍៖ **ក** បានដាក់សំណើលក់ដីមួយកន្លែងទៅឱ្យ **ខ** ក្នុងតម្លៃ ១០០ ០០០ដុល្លារ ហើយ ការដាក់សំណើបានផ្ញើរតាមរយៈប្រពន្ធ័ប្រៃសណីយ៍។ ហើយសំបុត្រនោះបានទៅដល់ផ្ទះរបស់ **ខ** តែភាគី **ខ** មិនបានអាននៅសំបុត្រនោះទេ ក្នុងករណីនេះសំណើត្រូវបានបង្កើតអានុភាពតាមការ កំណត់របស់ច្បាប់។ ប៉ុន្តែអានុភាពនៃសំណើនឹងមិនត្រូវបានកើតឡើងទេ ប្រសិនបើដំណឹងអំពីការ ដកសំណើនោះបានទៅដល់មុនពេល ឬពេលព្រមគ្នាដែរសំណើបានទៅដល់អ្នកទទួលសំណើ។ តាមរយៈកិច្ចសន្យាទិញលក់ដីខាងលើប្រសិនបើ **ក** បានធ្វើការទូរស័ព្ទប្រាប់ **ខ** អំពីការឈប់លក់វិញ មុនពេលដែល **ខ** បានទទួលសំណើ នោះនាំឱ្យសំណើនិងត្រូវបានបាត់បង់អានុភាព។

**១.២. ស្វីការ**

ស្វីការ គឺជាការបង្ហាញឆន្ទៈ ដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ[៥]។ ស្វីការ ត្រូវមានខ្លឹមសារដែលឆ្លើយតបដូចគ្នានឹងសំណើដែរ។ ការធ្វើស្វីការក្នុងការយល់ព្រមចំពោះសំណើ របស់អ្នកស្នើ វាអាស្រ័យទៅលើប្រភេទនីមួយៗនៃសំណើ ថាតើសំណើនោះជាសំណើដែលមានកំណត់អំឡុងពេលសម្រាប់ផ្តល់ស្វីការ ឬជាសំណើរដែលគ្មានកំណត់អំឡុងសម្រាប់ផ្តល់អ្វីការ។

**១.២.១. ការមកដល់យឺតយ៉ាវនៃស្វីការ**

ចំពោះសំណើដែលមានកំណត់អំឡុងពេល ករណីដែលការជូនដំណឹងអំពីស្វីការ មកដល់អ្នកស្នើក្រោយអំឡុងពេលសម្រាប់ធ្វើស្វីការ ប្រសិនបើអ្នកស្នើស្ថិតនៅក្នុងស្ថានភាព ដែលអាចដឹងថា ភាគីម្ខាងទៀតជូនដំណឹងអំពីស្វីការ នៅពេលដែលអាចមកដល់ក្នុងអំឡុងពេលសម្រាប់ស្វីការក្នុងករណីធម្មតា នោះអ្នកស្នើត្រូវជូនដំណឹងអំពីការមកដល់ស្វីការដោយមានការយឺតយ៉ាវនោះ ទៅអ្នកធ្វើស្វីការដោយគ្មានភាពយឺតយ៉ាវ។ ក្នុងករណីដែលអ្នកស្នើនោះមានការធ្វេសប្រហែសក្នុងការជូនដំណឹងអំពីការមកដល់យឺតយ៉ាវនៃស្វីការ នោះនាំឱ្យស្វីការមានសុពលភាព។ បន្ថែមពីលើនេះ ទៅទៀត ភាគីដែលដាក់សំណើអាចចាត់ទុកថា ស្វីការដែលមកដល់ក្រោយអំឡុងពេលសម្រាប់ស្វីការ គឺជាសំណើថ្មីបាន។

**១.២.២. ស្វីការដោយមានបន្ថែមការកែប្រែ**

ករណីដែលអ្នកធ្វើស្វីការ បានធ្វើការដាក់លក្ខខណ្ឌលើសំណើ ឬកែប្រែសារធាតុផ្សេងៗ នៃសំណើនោះ នាំឱ្យស្វីការមិនត្រូវបានក្លាយជាស្វីការដែលមានសុពលទេ តែស្វីការនោះមានអានុភាពជាសំណើថ្មីទៅវិញ។ យើងអាចដឹងថា ស្វីការដែលមានការដាក់លក្ខខណ្ឌ ឬការប្រែសារធាតុនៃសំណើបាន គឺអាស្រ័យទៅការបកស្រាយដោយផ្អែកទៅលើករណីនីមួយៗ។

---

[៥] មាត្រា ៣៣៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឧទាហរណ៍៖ ភាគី **ក** បានដាក់សំណើលក់ ផ្ទះមួយល្វែងទៅ ភាគី **ខ** ក្នុងតម្លៃ ៣០០០០ដុល្លារ តែភាគី **ខ** ព្រមទិញផ្ទះនោះនៅក្នុងតម្លៃ ២៥០០០ដុល្លារ ។ ការផ្តល់ស្ទីការរបស់ភាគី ខ បែបនេះត្រូវ ចាត់ទុកថាជាស្ទីការដោយមានការដាក់ល័ក្ខខ័ណ្ឌ។ ដូច្នេះ កិច្ចសន្យានឹងមិនត្រូវកើតឡើងនោះទេ ប្រសិនបើអ្នកដាក់សំណើដើមមិនបានផ្តល់ស្ទីការចំពោះសំណើថ្មីនោះ។ ប៉ុន្តែ ប្រសិនបើការដាក់លក្ខខណ្ឌ ឬការកែប្រែភ្ជាប់ជាមួយនឹងស្ទីការមិនធ្វើឱ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះនឹងមានសុពលភាព ប្រសិនបើភាគីម្ខាងទៀតមិនព្រមធ្វើការតវ៉ាភ្លាមៗ។

ឧទាហរណ៍៖ **ក** លក់ម៉ូតូមួយគ្រឿងក្នុងតម្លៃ ២០០០ដុល្លារ ទៅភាគី **ខ** ហើយបន្ទាប់មកភាគី **ខ** យល់ព្រមទិញដោយគ្រាន់តែឱ្យភាគី **ក** ធ្វើការលាងសម្អាតម៉ូតូនោះ។ ក្នុងករណីនេះ ការផ្តល់ស្ទីការ របស់ភាគី **ខ** គឺមិនបានកែប្រែសារធាតុនៃសំណើនោះឡើយ ហើយកិច្ចសន្យានឹងកើតមានឡើង ប្រសិនបើភាគី **ក** មិនបានធ្វើការតវ៉ាចំពោះស្ទីការនេះ ។

### ១.២.៣. អានុភាពនៃស្ទីការ

ស្ទីការ មានអានុភាពនៅពេលដែលស្ទីការនោះបានទៅដល់ភាគីម្ខាងទៀត ពោលគឺនៅពេលដែលអ្នកធ្វើសំណើ បានទទួលដំណឹងអំពីស្ទីការនោះ។ ប្រសិនបើដំណឹងអំពីការដកស្ទីការវិញ បានទៅដល់ក្នុងអំឡុងពេល ឬមុនពេលស្ទីការបានទៅដល់អ្នកស្នើវិញនាំឱ្យស្ទីការមិនមានអានុភាពឡើយ។

ឧទាហរណ៍៖ **ក** ដាក់សំណើដើម្បីលក់រថយន្តមួយគ្រឿងក្នុងតម្លៃ ២០០០០ដុល្លារ ទៅភាគី **ខ** បន្ទាប់ពីបានទទួលសំណើ ភាគី **ខ** បានផ្តល់ស្ទីការទិញរថយន្តនោះពីភាគី **ក** តាមរយៈការសរសេរសំបុត្រ ប៉ុន្តែបន្តិចក្រោយមកភាគី **ខ** បានផ្លាស់ប្តូរចិត្តឈប់ទិញរថយន្តវិញហើយបានទូរសព្ទ័ទៅ ប្រាប់ភាគី **ក** មុនពេលដែលស្ទីការបានទៅដល់ភាគី **ក**។ នៅក្នុងករណីនេះស្ទីការមិនត្រូវបានបង្កើត អានុភាពទេ ។

## ១.៣. អញ្ញត្រកម្ម

ជាគោលការណ៍ កិច្ចសន្យាត្រូវបានបង្កើតឡើងនៅពេលសំណើ និងស្ទីការត្រូវគ្នា។ ទោះបីជា សំណើនិងស្ទីការត្រូវគ្នាក៏ដោយ ប្រសិនបើករណីដែលកិច្ចសន្យាតម្រូវឱ្យភាគីម្ខាងដែលទទួលករណីយកិច្ច ធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ វានឹងមិនបង្កើតអានុភាពទេ ប្រសិនបើមិនធ្វើជាលិខិតយថាភូត[៩] ។ បានសេចក្តីថា កិច្ចសន្យាដែលភាគី ម្ខាងមានករណីយកិច្ចធ្វើអនុប្បទាន ឬធ្វើលទ្ធកម្មកម្មសិទ្ធលើអចលនវត្ថុ នឹងមិនមានអានុភាព ប្រសិនបើកិច្ចសន្យានោះធ្វើឡើងដោយផ្ទាល់មាត់ ឬដោយលិខិតឯកជន ពីព្រោះវាទាមទាឱ្យភាគី ធ្វើជាលិខិតយថាភូតទើបអានុភាពនៃកិច្ចសន្យាកើតមានតាមផ្លូវច្បាប់បាន។ កិច្ចសន្យាលក់ទិញ អចលនវត្ថុ គឺជាប្រភេទមួយនៃកិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើ

[៩] មាត្រា ៣៣៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចផ្ទេលទ្ធកម្មនូវសិទ្ធិលើអចលនវត្ថុ ហេតុនេះកិច្ចសន្យាលក់ទិញ អចលនវត្ថុមានអានុភាពទៅបាន លុះត្រាកិច្ចសន្យាលក់ទិញអចលនវត្ថុត្រូវធ្វើជាលិខិតយថាភូត។

## ផ្នែកទី ២ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា

បន្ទាប់ពីសំណើ និងស្ទីការបានត្រូវគ្នា នាំឱ្យកិច្ចសន្យាបានកើតឡើង ហើយនាំឱ្យមានអានុភាពចងភ្ជាប់នូវកាតព្វកិច្ចភាគី ដែលនាំឱ្យអនុវត្តតាមកិច្ចសន្យា។ ប៉ុន្តែទោះបីជា កិច្ចសន្យានោះមានអានុភាពក៏ដោយ ករណីខ្លះអានុភាពរបស់កិច្ចសន្យានោះអាចនឹងត្រូវបានបដិសេធទៅវិញ ប្រសិនបើកិច្ចសន្យាត្រូវបានបង្ហាញឆន្ទៈលុបចោល ដោយមូលហេតុមួយចំនួនដូចជា៖ មានវិការៈក្នុងការបង្ហាញឆន្ទៈ ឬភាគីនៃកិច្ចសន្យាជាជនដែលត្រូវបានកម្រិតសមត្ថភាព។ ហេតុនេះ ដើម្បីឱ្យកិច្ចសន្យាមួយមានអានុភាពអនុវត្តទៅបានប្រកបដោយភាពត្រឹមត្រូវ ដោយមិនត្រូវរងនូវការលុបចោលរបស់ភាគីម្ខាងទៀត ហើយកិច្ចសន្យាត្រូវគោរពតាមលក្ខខណ្ឌពីរ គឺលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

### ២.១. លក្ខខណ្ឌគ្រឹះ

#### ២.១.១. សមត្ថភាពគតិយុត្តទាក់ទងនឹងភាគី

សមត្ថភាព គឺភាពជាអ្នកមានអាយុគ្រប់គ្រាន់ មានវិចារណញ្ញាបូរិបូរអាចប្រើសិទ្ធិគ្រប់បែបយ៉ាងរបស់ខ្លួនបាន ភាពដែលអាចយល់ដឹងពីធម្មជាតិ និងផលនៃអំពើរបស់ខ្លួន។

តាមសន្ទានុក្រម នៃក្រមរដ្ឋប្បវេណី សមត្ថភាព សំដៅទៅលើលក្ខណៈសម្បត្តិ ៣យ៉ាងដែលច្បាប់តម្រូវរួមមាន[10]៖

- សមត្ថភាពទទួលបាននូវសិទ្ធិ
- សមត្ថភាពខាងឆន្ទៈ
- សមត្ថភាពក្នុងការធ្វើសកម្មភាព។

##### ២.១.១.១. សមត្ថភាពទទួលបាននូវសិទ្ធិ

លក្ខណៈសម្បត្តិដែលក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចហៅថា សមត្ថភាពទទួលសិទ្ធិ[11]។ ជាគោលការណ៍គ្រប់រូបវន្តបុគ្គលមិនថាជាជនជាតិខ្មែរ ឬបរទេសអាចទទួលបាននូវសិទ្ធិបុគ្គលដូចៗគ្នា។ ការកម្រិតសិទ្ធិខ្លះចំពោះជនបរទេសដែលរស់នៅលើទឹកដីកម្ពុជា គឺថាជនបរទេសមិនអាច ទទួលបាននូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ក្នុងច្បាប់ជាតិ សន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិឡើយ[12]។

---

[10] សន្ទានុក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកមពុជា ឆ្នាំ២០០៧ ទំព័រទី២១

[11] មាត្រា ៦ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[12] មាត្រា ៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ បានចែងថា "មានតែរូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបអាចទទួលបាននូវសិទ្ធិលើដីធ្លី"[13] ។ ហេតុនេះជនបរទេសមិនអាចក្លាយជាម្ចាស់កម្មសិទ្ធិដីធ្លីនៅកម្ពុជាបានទេ។ ប៉ុន្តែច្បាប់ជាតិរបស់ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន មានការអភិវឌ្ឍន៍បានផ្តល់នូវសិទ្ធិកាន់កាប់លើចំណែកអគារសហកម្មសិទ្ធិមួយចំនួនដល់ជនបរទេស[14]។ ផ្អែកតាមគោលគំនិតនេះ ការផ្តល់នូវសិទ្ធិកាន់កាប់លើអគារសហកម្មសិទ្ធិដល់ជនបរទេស ដើម្បីសម្រួល ដល់ការវិនិយោគទុនរបស់ជនបរទេសលើទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា និងជាពិសេសទៅលើ វិស័យសំណង់ ស្របពេលដែលទីផ្សារអចលនវត្ថុកម្ពុជាបច្ចុប្បន្នកំពុងតែមានសន្ទុះនៃការរីកចម្រើនទៅមុខជាលំដាប់ឥតឈប់ឈរ។

**២.១.១.២. សមត្ថភាពខាងឆន្ទៈ**

សមត្ថភាពខាងឆន្ទៈ គឺសំដៅលើសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផល តាមផ្លូវច្បាប់នៃសកម្មភាព (អាចជាកិច្ចសន្យា ឬសកម្មភាពឯកតោភាគី)របស់ខ្លួនបាន។ ផ្ទុយមកវិញ ករណីប្រសិនបើមានការខ្វះសមត្ថភាពខាងឆន្ទៈ វាអាចបណ្តាលឱ្យសកម្មភាពគតិយុត្តទាំងនោះ ប្រឈមមុខទៅនឹងការលុបចោលរបស់ភាគីដែលខ្វះសមត្ថខាងឆន្ទៈ[15]។ ការខ្វះសមត្ថភាពខាងឆន្ទៈ នៅក្នុងន័យនេះ គឺមិនសំដៅទៅលើជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពនោះទេ។ ដូចនេះ ជនដែលខ្វះសមត្ថភាពខាងឆន្ទៈនៅក្នុងន័យនេះ គឺអាចជាជនដែលស្ថិតនៅក្នុងស្ថានមួយ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារតែមានបញ្ហាខាងបញ្ញាស្មារតី តែមិនទាន់ត្រូវបានប្រកាសរបបណាមួយនៅឡើយ ឬអាច ជាជនដែលមានសមត្ថភាពធម្មតា តែនៅក្នុងពេលធ្វើសកម្មភាពរបស់ខ្លួន ជននេះបានស្ថិតនៅក្នុង ស្ថានភាពមួយដែលខ្វះសមត្ថភាពខាងឆន្ទៈ។

ឧទាហរណ៍៖ **ក** ចុះកិច្ចសន្យាលក់ផ្ទះមួយល្វែងក្នុងតម្លៃ ២០០០០ដុល្លារជាមួយ **ខ** នៅក្នុង ស្ថានភាពមួយដែលកំពុងស្រវឹងស្រា ហើយដែលតម្លៃដែលដាក់លក់នោះ គឺស្ថិតនៅក្នុងតម្លៃមួយ ដែលទាបជាងតម្លៃទីផ្សារយ៉ាងខ្លាំង។ ដូច្នេះ **ក** អាចធ្វើការលុបចោលនូវកិច្ចសន្យារបស់ខ្លួនជាមួយ **ខ** បាន ដោយសារតែ នៅពេលធ្វើកិច្ចសន្យា **ក** បានស្ថិតនៅក្នុងស្ថានភាពមួយចុះខ្សោយយ៉ាងខ្លាំង ក្នុងការវិនិច្ឆ័យអំពីសកម្មភាពរបស់ខ្លួន។

ដូច្នេះ ការកម្រិតនូវសកម្មភាពខាងឆន្ទៈក្នុងគោលបំណង ដើម្បីការពារកុំឱ្យមានការខូចខាត ដល់កិច្ចការជំនួញរបស់បុគ្គលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផល តាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។

---

[13] មាត្រា ៨៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

[14] ច្បាប់ ស្តីពីការផ្តល់សិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១០

[15] មាត្រា ១៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

#### ២.១.១.៣. សមត្ថភាពក្នុងការធ្វើសកម្មភាព

សមត្ថភាពក្នុងការធ្វើសកម្មភាព សំដៅទៅលើសមត្ថភាពដែលបុគ្គលម្នាក់អាចបង្ហាញឆន្ទៈប្រកបដោយ ប្រសិទ្ធិភាពនូវការសម្រេចចិត្តរបស់ខ្លួនផ្ទាល់ ហើយមានលក្ខណៈសម្បត្តិធ្វើសកម្មភាពគតិយុត្តដោយឯករាជ្យ មិនចាំបាច់មានជំនួយពីអ្នកដទៃឡើយ[16] ។ ជាគោលការណ៍ រូបវ័ន្តបុគ្គល គ្រប់រូបមានសមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត ហេតុនេះដើម្បីរក្សានូវគោលការណ៍មូលដ្ឋាន ទើបមានការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត របស់បុគ្គលដែលមិនមានសមត្ថភាព គ្រប់គ្រាន់ក្នុងការធ្វើសកម្មភាព។ ហេតុនេះច្បាប់បានតម្រូវឱ្យមានជំនួយពីអ្នកដទៃ (អ្នកតំណាង) ក្នុងការធ្វើសកម្មភាព។

ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព តម្រូវឱ្យមានការអនុញ្ញាតយល់ព្រម ពីអ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈរបស់ជននោះជាមុនសិន មុនពេលធ្វើការបង្ហាញឆន្ទៈរបស់ខ្លួន។ ប្រសិនបើជនដែលត្រូវកម្រិតសមត្ថភាព បានធ្វើសកម្មភាពដោយគ្មាន ការអនុញ្ញាតពីអ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈ សម្រាប់សកម្មភាពរបស់ជននោះ អាចត្រូវបានលុបចោលបានតាមរយៈអ្នកតំណាង ឬហិតូបត្ថម្ភកៈរបស់ជនទាំងនោះ។ ចំពោះសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ឬទទួលបានសិទ្ធិ ឬសកម្មភាពរួចផុតពីកាតព្វកិច្ចមិនត្រូវបានលុបចោលទេ។ ដូច្នេះជនទាំងនោះត្រូវបានចាត់ទុកថា ជាជនត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើ សកម្មភាព។ ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពនោះមានដូចជា អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។

### ២.១.២. មិនត្រូវមានវិការៈនៃការព្រមព្រៀង

ការបង្ហាញឆន្ទៈដោយស្មោះត្រង់ ដោយសេរី និងមិនមានវិការៈ គឺជាការព្រមព្រៀងដោយ ពិតប្រាកដ។ ការបង្ហាញឆន្ទៈដោយពិតប្រាកដ និងបង្កើតឲ្យមានអានុភាពចំពោះភាគីសងខាងនៃកិច្ចសន្យា តែបើកិច្ចសន្យាមានវិការៈវិញ កិច្ចសន្យានឹងត្រូវបដិសេធអានុភាពនៃការបង្ហាញឆន្ទៈ។ មានន័យថា ភាគីដែលយល់ព្រមចុះកិច្ចសន្យា គឺគិតខុសពីកម្មវត្ថុដែលខ្លួនរំពឹងថានឹងត្រូវទទួលបាន ឬផ្តល់ឲ្យភាគីម្ខាងទៀត ហើយវាក៏អាចជាការយល់ច្រឡំមួយទៅលើបុគ្គល ដែលចុះកិច្ចសន្យានោះផងដែរ។ វិការៈដែលភាគីនៃកិច្ចសន្យាគួរជៀសវាង នឹងមិនត្រូវបង្កើតក្នុងកិច្ចសន្យាមានដូចខាងក្រោមនេះ៖

#### ២.១.២.១. ការភាន់ច្រឡំ

##### ក. ការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា

កិច្ចសន្យា អាចត្រូវបានលុបចោលទៅវិញ ប្រសិនបើកិច្ចសន្យានោះ ត្រូវបានធ្វើឡើងដោយមានការភាន់ច្រឡំទៅលើចំណុចសំខាន់ៗនៃកិច្ចសន្យា ខណៈដែល ភាគីម្ខាងទៀត បានស្ថិតនៅក្នុងស្ថានភាពដែល

[16] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១-២ ទំព័រទី១៦ ឆ្នាំ២០១៣

អាចដឹងបានអំពីការភាន់ច្រឡំនោះ[17]។

អត្ថន័យនៃ "ចំណុចសំខាន់ៗនៃកិច្ចសន្យា" តើគេអាចកំណត់ "ចំណុចសំខាន់ៗនៃកិច្ចសន្យា" ដោយរបៀបណា?

វាជាការពិបាកណាស់ក្នុងការកំណត់អំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ដែលជាហេតុអាចឱ្យភាគីលុបចោលកិច្ចសន្យា ដែលខ្លួនបានបង្កើតឡើងដោយមូលហេតុនៃការភាន់ច្រឡំ ព្រោះពុំមានមាត្រាច្បាប់ណាមួយចែងច្បាស់អំពីចំណុចសំខាន់ៗនោះទេ។ វាត្រូវបានសម្រេចដោយធ្វើការពិចារណា ទៅលើខ្លឹមសារនៃកិច្ចសន្យា។ ជាធម្មតា គេអាចនិយាយបាន "ប្រសិនបើគាត់មិនមានការភាន់ច្រឡំនោះទេ គាត់ក៏មិនបង្ហាញឆន្ទៈព្រមព្រៀងដែរ" ។

ដូច្នេះគេអាចចាត់ទុកថាជា "ចំណុចសំខាន់ៗ នៃកិច្ចសន្យា"។

ឧទាហរណ៍៖ **ក** បានចរចាលក់ដើមស្វាយកែវល្មៀត ចំនួន ១០ ដើម ទៅឱ្យ **ខ** ក្នុងតម្លៃ ១០.000 រៀលក្នុង ១ ដើម។ ប៉ុន្តែការពិតដើមស្វាយដែល **ក** បានលក់នោះ គឺជាដើមស្វាយប្រភេទ ស្វាយកែវចិន ទៅវិញ ហើយដើមស្វាយប្រភេទនេះ មានតម្លៃដល់ទៅ ២0.000 រៀល ក្នុងមួយដើម ឯណោះ។ តើ **ក** អាចលុបចោលកិច្ចសន្យាលក់ទិញនេះ បានដែរឬទេ? ចម្លើយ គឺពិតជាបាន ពីព្រោះ ថាប្រសិនបើ **ក** បានដឹងថាដើមស្វាយនោះ ជាដើមស្វាយកែវចិននោះ ខ្លួនក៏មិនលក់វាក្នុងតម្លៃនេះដែរ ។

ផ្ទុយទៅវិញ **ក** បានដឹងថាគាត់បានលក់ដើមស្វាយកែវចិន ហើយបានកំណត់កាលបរិច្ឆេទប្រគល់ដែលខុស ពីឆន្ទៈពិតរបស់គាត់ នោះគេមិនអាចនិយាយថា វាគឺជាចំណុចសំខាន់នៃកិច្ចសន្យាទេ ។

ដើម្បីលុបចោលកិច្ចសន្យា លទ្ធភាពនៃការដឹងរបស់ភាគីម្ខាងទៀត គឺតម្រូវឱ្យមានដូចខាងក្រោម ។

### ខ. ការភ័ន្តច្រឡំទៅលើចំណុចនៃកិច្ចសន្យា ដែលគូភាគីយល់ឃើញថាសំខាន់

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យា ដែលខ្លួន យល់ឃើញថាសំខាន់ ឬចំណុចដែលខ្លួន យល់ឃើញថាសំខាន់ក្នុងការបង្កើត កិច្ចសន្យា បើភាគីម្ខាងទៀត បានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និងការភាន់ច្រឡំរបស់ អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាច លុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[18]។

តើ "ចំណុច នៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់ មានន័យយ៉ាងដូចម្តេច?

ចំណុចដែលភាគីយល់ឃើញថាសំខាន់នេះ អាចមិនមែនពាក់ព័ន្ធទៅនឹងកម្មវត្ថុចម្បងនៃកិច្ចសន្យាទេ ហើយវាមិនមែនសំខាន់សម្រាប់ភាគីទាំងសងខាងនោះទេ គឺវាមានសារៈសំខាន់សម្រាប់តែគីម្ខាងប៉ុណ្ណោះ ។

---

[17] មាត្រា ៣៨៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[18] មាត្រា ៣៨៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ឧទាហរណ៍៖ ជាទូទៅ ខ្លឹមសារនៃសៀវភៅ គឺមានសារៈសំខាន់ណាស់នៅពេលដែលបុគ្គលណាម្នាក់ទិញសៀវភៅ។ ក៏ប៉ុន្តែ សម្រាប់អ្នកដែលមានចំណង់ចំណូលចិត្តក្នុងការប្រមូលទិញ សៀវភៅដែលបោះពុម្ពលើកទី១នោះ គឺថា តើសៀវភៅនោះ គឺជាសៀវភៅដែលបោះពុម្ពលើកទី ១ ឬ មិនមែន គឺពិតជាមានសារៈសំខាន់ជាងខ្លឹមសារ ខាងក្នុងសៀវភៅទៅទៀត ។ ផ្ទុយទៅវិញ អ្នកលក់មិនអាចដឹងបានដោយងាយស្រួលនោះទេ ថាតើអ្នកទិញនោះ ចង់ទិញសៀវភៅដែលបោះពុម្ពលើកទី១ ឬមិនមែន ។ ដូច្នេះ ឧទាហរណ៍ថា នៅក្នុងករណីដែលអ្នកទិញដែលជាអ្នកមានចំណង់ចំណូលចិត្តក្នុងការប្រមូលទិញសៀវភៅ ដែលបោះពុម្ពលើកទី១នោះ បានទិញសៀវភៅដែលមិនមែនបោះពុម្ពលើកទី១ អ្នកទិញនោះ អាចលុបចោលកិច្ចសន្យាបាន តែក្នុងករណីដែលអ្នកលក់បានស្ថិតនៅក្នុងស្ថានភាពដែលអាច ដឹងថាអ្នកទិញនោះ ចង់ទិញសៀវភៅដែលបោះពុម្ពលើកទី១ ហើយគាត់បានទិញសៀវភៅដែលមិនមែនជាការបោះ ពុម្ពលើកទី១ ដោយមានការភាន់ច្រឡំ ។

### គ. ការភាន់ច្រឡំដោយភាគីទាំងសងខាង

ក្នុងករណីដែលភាគី ទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗ នៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យា ដែលភាគីទាំងសខាងយល់ឃើញថាសំខាន់ ឬចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[19]។

### ឃ. ការការពារតតិយជន

ការលុបចោលកិច្ចសន្យាដោយការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុស អំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចំពោះតតិយជននោះបានឡើយ[20]។

ឧទាហរណ៍៖ **ក** បានលក់រថយន្តរបស់ខ្លួនទៅឱ្យ **ខ** ដោយមានការភាន់ច្រឡំ ហើយ **ខ** បានលក់រថយន្តនេះទៅឱ្យ **គ** ។ ប្រសិនបើ **ក** លុបចោលកិច្ចសន្យា នោះអានុភាពនៃកិច្ចសន្យានឹងត្រូវបានចាត់ទុកថាមោឃៈតាំងពីដំបូង (មាត្រា ៣៥៨ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧) ។

**២.១.២.២. ការឆបោក**

ការបង្ហាញឆន្ទៈដោយការឆបោក មានន័យថាបុគ្គលណាម្នាក់ ឬ តតិយជន បានធ្វើឱ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំដោយសារមធ្យោបាយឆបោក ហើយអ្នកបង្ហាញឆន្ទៈ បានបង្ហាញ ឆន្ទៈរបស់ខ្លួនដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន និង គាត់មិនបានដឹងពីភាពខុសគ្នានេះ នៅពេលដែលគាត់ធ្វើការបង្ហាញឆន្ទៈ។

[19] មាត្រា ៣៤៦ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[20] មាត្រា ៣៤៦ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

បុគ្គលដែល បានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[21]។

ឧទាហរណ៍៖ លោក **ក** បានបន្លំប្រើឋានៈជាមេធាវី ធ្វើកិច្ចសន្យាទិញដីពី លោក **ខ** ឲ្យទៅ លោក **គ** ក្នុងតម្លៃ ៤ពាន់ដុល្លា ដោយកំណត់ថ្ងៃប្រគល់ប្រាក់ ២សប្តាហ៍គិតចាប់ពីថ្ងៃចុះកិច្ចសន្យាលក់ទិញដី។ ដោយការមមាញឹកនឹងមុខរបររកស៊ីផង និងជឿទុកចិត្តលើមេធាវី **ក** ផង លោក **គ** បានប្រគល់ប្រាក់គ្រប់ចំនួនឲ្យលោកមេធាវី **ក** យកទៅទិញដីពី លោក **ខ** និង រត់ឯកសារជូនគាត់។ តែដោយសារលោក **ក** ជាជនទុចរិត ក្លែងបន្លំខ្លួនជាមេធាវី ក្រោយពីទទួលបានប្រាក់ហើយ លោក **ក** ក៏បានយកប្រាក់នោះរត់បាត់។ យោងតាមអង្គហេតុខាងលើ លោក **គ** បានបង្កើតកិច្ចសន្យាជាមួយ លោក **ខ** ដោយការឆបោករបស់ លោក **ក** ដែលតាំងខ្លួនបន្លំជា មេធាវី បង្កើតកិច្ចសន្យាលក់ទិញពី លោក **ខ** ឲ្យទៅលោក **គ** ។

ក្នុងករណីនេះ ប្រសិនបើលោក **គ** ចង់លុបចោលកិច្ចសន្យានោះ គឺគាត់ពុំអាចធ្វើទៅបានទេ កាលបើលោក **ខ** ជាជនសុចរិត គ្មានកំហុសអំពីការឆបោកនោះ[22] ។ មានន័យថា ការលុប ចោលកិច្ចសន្យាដែលធ្វើឡើងដោយការឆបោករបស់តតីយជន នឹងត្រូវបានអនុញ្ញាត លុះត្រាតែ ភាគីម្ខាងទៀត លោក **ខ** បានដឹង ឬ អាចដឹងអំពីការឆបោកនោះ[23]។

ការឆបោកមានលក្ខណៈស្រដៀងគ្នាទៅនឹងការភាន់ច្រឡំ ត្រង់ចំណុចដែលឆន្ទៈពិតប្រាកដ និង ការបង្ហាញ ឆន្ទៈចេញមកក្រៅមិនត្រូវគ្នា។ ក៏ប៉ុន្តែ ភាពខុសគ្នានេះកើតឡើងពីសកម្មភាពឆបោករបស់ភាគីម្ខាងទៀត ឬ តតិយជន នៅក្នុងករណីនៃការឆបោក ដែលមានលក្ខណៈខុសគ្នាពីការភាន់ច្រឡំ[24]។

**២.១.២.៣. ព័ត៌មានមិនពិត**

សិទ្ធិលុបចោលកិច្ចសន្យា ត្រូវបានផ្តល់ឲ្យអ្នកបង្ហាញឆន្ទៈ ករណីការបង្ហាញឆន្ទៈធ្វើឡើង ដោយសារការផ្តល់ពត៌មានមិនពិត តាមរយៈភាគីម្ខាងទៀតនៃកិច្ចសន្យា។ នៅក្នុងករណីដែលភាគី ម្ខាងទៀតបង្ហាញពត៌មានមិនពិតដោយចេតនា សកម្មភាពនេះនឹងក្លាយទៅជាការឆបោក ហើយប្រសិនបើ អ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ ហេតុដូច្នេះ ការលុបចោលកិច្ចសន្យាអាចអនុញ្ញាត ដោយហេតុផល នៃការភាន់ច្រឡំ។ ការលុបចោលកិច្ចសន្យាអាចអនុញ្ញាតទៅបាន លុះត្រាតែការ ភាន់ច្រឡំនោះ ទាក់ទងនឹងចំណុចសំខាន់ៗនៃកិច្ចសន្យា និងភាគីម្ខាងទៀតមានលទ្ធភាពក្នុងការដឹងអំពីការភាន់ច្រឡំ។

[21] មាត្រា ៣៤៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[22] មាត្រា ៣៤៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[23] មាត្រា ៣៤៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[24] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ១-២ ទំព័រ ១២៧

លើសពីនេះទៅទៀត ភាគីដែលបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត មិនត្រឹមតែត្រូវបានអនុញ្ញាតឲ្យលុបចោលកិច្ចសន្យាប៉ុណ្ណោះទេ តែក៏មានសិទ្ធិទាមទារ នូវសំណងនៃការខូចខាតដែលនៅសល់ក្រោយកិច្ចសន្យាបានដែរ ឬក៏ទុកកិច្ចសន្យាឲ្យមានអានុភាពបន្ត តែទាមទារសំណងនៃការខូចខាតដែលកើតមានដោយភាគីបង្ហាញពត៌មានមិនពិត។ ចំពោះ ទំហំនៃការខូចខាតវិញគឺពិតជាមានការលំបាកក្នុងការកំណត់ថាវាមានទំហំប៉ុណ្ណាណាស់ គឺអាស្រ័យលើ ការបកស្រាយតាមរយៈគតិយុត្តិសាស្ត្រ និងទ្រឹស្តី នាពេលអនុវត្តរឿងហេតុជាក់លាក់[25]។ ផ្ទុយទៅវិញ ការលុបចោលកិច្ចសន្យាមិនអាចធ្វើទៅបានទេ ប្រសិនបើតតិយជន ជាជនសុចរិត ហើយគ្មានកំហុសពីពត៌មានមិនពិត ។ មានន័យថា តតីយជនគឺមិនបានដឹងហេតុផលនៃពត៌មានមិនពិតនោះទេ ហេតុដូច្នេះ ប្រសិនបើការលុបចោលកិច្ចសន្យាត្រូវបានអនុញ្ញាត នោះនឹងនាំឲ្យតតីយជនខូចប្រយោជន៍[26]។

### ២.១.២.៤. ការរំលោភលើស្ថានភាព

នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យា បានប្រើឋានៈមួយដែលមាន អាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេង ទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះ អាចលុបចោល នូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ[27]។

ឧទាហរណ៍៖ នៅក្នុងករណីដែលនិយោជកបានប្រើឋានៈរបស់ខ្លួន ឱ្យនិយោជិតទិញនូវវត្ថុអ្វីពីខ្លួននោះ នោះនិយោជិកអាចលុបចោលកិច្ចសន្យាចោលបាន ព្រោះគាត់អាចត្រូវបានបង្ខំឱ្យទិញវត្ថុនោះ ទោះបីជាគាត់មិនចង់ទិញក៏ដោយ។

ការលុបចោលនូវកិច្ចសន្យា ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ[28]។

### ២.១.២.៥. ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈ ដោយសារការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬពីសំណាក់តតិយជន អាចលុបចោលនៅកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[29]។

ឧទាហរណ៍៖ លោក **គ** បានចាប់កូនស្រីរបស់លោក **ខ** ដើម្បីគម្រាមឲ្យយល់ព្រមចុះកិច្ចសន្យាលក់ដីឯកជនរបស់រដ្ឋមួយកន្លែង ទំហំ ៩០ ហិចតា ទៅឲ្យអ្នកតំណាងរបស់ប្រទេស **គ** ។ ផ្អែកទៅលើស្ថានភាពគម្រាម

---

[25] សូមមើលមាត្រា ៣៨៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[26] មាត្រា ៣៨៨ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[27] មាត្រា ៣៨៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[28] មាត្រា ៣៨៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[29] មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

កំហែងយ៉ាងធ្ងន់ធ្ងរបែបនេះ លោក **ខ** អាចបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាព្រមលក់ដីនោះបាន ដោយគ្មានលក្ខខណ្ឌ ទោះបីជាភាគីម្ខាងទៀតនៃកិច្ចសន្យាលោក **គ** មិន បានដឹងអំពីការគម្រាមកំហែងនេះក៏ដោយ។

### ២.១.២.៦. ការកេងចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ខ្វះបទពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[30]។

ជាទូទៅ សកម្មភាពបែបនេះយើងតែងតែឃើញកើតមានទៅលើប្រជាជនក្រីក្រនៅតាមជនបទ ជាជាងនៅក្នុងទីក្រុង។ ជាពិសេសក្នុងមុខជំនួញ ដែលភាគីម្ខាងហៅថាអាជីវករ បានឆ្លៀតឱកាសកេញយកចំណេញហួសហេតុពីអ្នកទិញ ឬអ្នកប្រើប្រាស់។ ប៉ុន្តែបើយើងអនុញ្ញាត ឲ្យមានការលុបចោលកិច្ចសន្យាងាយស្រួលពេកហាក់បីដូចជាកិច្ចសន្យាពុំមានតម្លៃ។ ដើម្បីឲ្យការលុបចោលកិច្ចសន្យាអាចធ្វើទៅបាន ចាំបាច់ត្រូវតែពិនិត្យថា តើកិច្ចសន្យានោះធ្វើឡើងដោយការកេងយកចំណេញហួសហេតុ ឬយ៉ាងណា។ ការកេញយកចំណេញហួសហេតុគឺពុំបានកំណត់និយមន័យ និងទំហំណាមួយជាគោលក្នុងក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ ២០០៧ នោះទេ ហេតុនេះចាំបាច់ឲ្យមានការ វិនិច្ឆ័យតាមរយៈការប្រើយុត្តិសាស្ត្រ អនុលោមតាមពេលវេលា និង ស្ថានភាព។

គួរពិចារណាផងដែរថា បញ្ញត្តិដែលចែងពីការកេងយកចំណេញហួសហេតុនេះ ស្រដៀងទៅនឹងបញ្ញត្តិស្តីពីការរំលោភបំពានលើស្ថានភាពដែរ តែអ្វីដែលខុសគ្នាគឺទំហំ នៃការបង្ខំភាគីម្ខាងទៀត។ ការកេញចំណេញហួសហេតុ មានទំហំតូចជាងការរំលោភបំពានលើស្ថានភាព ពីព្រោះថាបើយើង និយាយពី អំពើដែលភាគីម្ខាងនៃកិច្ចសន្យាប្រើមកលើភាគីបង្ហាញឆន្ទៈ ដោយការរំលោភបំពានលើស្ថានភាព គឺមិនបានទុកឱកាសឲ្យភាគីដែលត្រូវបានរំលោភបំពានធ្វើការប្រឆាំងតបទេ ។

### ២.១.២.៧. ឋបនីយផ្លូវចិត្ត

ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថា ខុសឆន្ទៈពិតរបស់ខ្លួន នោះកិច្ចសន្យា មិនត្រូវរារាំងនូវអានុភាពឡើយ។ ប៉ុន្តែ ក្នុងករណី ដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន[31] ។

---

[30] មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[31] មាត្រា ៣៥២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ឋបនីយផ្លូវចិត្ត គឺជាការបង្ហាញឆន្ទៈដែលធ្វើដោយដឹងថា ការបង្ហាញឆន្ទៈនោះមិនពិតទេ ។ ឧទាហរណ៍ A បង្ហាញឆនៈ ធ្វើប្រទានកម្ម ឱ្យទៅ B ទោះបីជា A គ្មានបំណងធ្វើបែបនេះក៏ដោយ ក៏ការបង្ហាញឆន្ទៈដែលមិនពិត គឺជាការបង្ហាញឆន្ទៈដែលមានវិការៈ ហើយតាមគោលការណ៍នៃកិច្ចសន្យាដែលមានការបង្ហាញឆន្ទៈដែលមានវិការៈអាចលុបចោលបាន។ ហើយ A ហាក់ដូចជាត្រូវបានអនុញ្ញាតឱ្យលុបចោលកិច្ចសន្យាប្រទានកម្ម ប៉ុន្តែការអនុញ្ញាតឱ្យលុបចោល ក្នុងករណីនេះ ធ្វើឱ្យខូចប្រយោជន៍របស់ B យ៉ាងខ្លាំង ប្រសិនបើ B មិនដឹងថា ការបង្ហាញឆន្ទៈរបស់ A មិនពិតទេ ។ បន្ថែមពីនេះ ដោយសារ A បង្ហាញឆន្ទៈមិនពិត ដោយដឹងថា ការបង្ហាញឆន្ទៈនោះមិនពិតវាមិនចាំបាច់ការពារអ្នកបង្ហាញឆន្ទៈ A ដែលបានឆ្លើយឋបនីយផ្លូវចិត្តទេ ហេតុដូច្នេះ កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយ ឋបនីយផ្លូវចិត្ត មានសុពលភាព ។

ប្រសិនបើ ភាគីម្ខាងទៀតដឹងអំពីឋបនីយផ្លូវចិត្តរបស់អ្នកបង្ហាញឆន្ទៈ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។ ករណីនេះ មិនមែនមានន័យថា ការបដិសេធនូវអានុភាពនៃកិច្ចសន្យាទេ។

## ២.១.៣. កម្មវត្ថុនៃកិច្ចសន្យា ឬលក្ខខណ្ឌមោឃៈភាពនៃកិច្ចសន្យា

កម្មវត្ថុនៃកិច្ចសន្យា គឺជាល័ក្ខខ័ណ្ឌមួយដែលត្រូវបានបំពេញ ដើម្បីឱ្យកិច្ចសន្យាមានសុពលភាព។ ជាទូទៅកម្មវត្ថុនៃកិច្ចសន្យាមានពីរប្រភេទ អាចជាវត្ថុ ឬសកម្មភាពរបស់ភាគី។ ដើម្បីឲ្យកិច្ចសន្យាមួយមានសុពលភាព ដរាបណាតែកម្មវត្ថុនៃកិច្ចសន្យាអាចអនុវត្តបានដោយមិនផ្ទុយពីបញ្ញត្តិស្តីពីការអនុវត្តដោយបង្ខំ ឬមិនផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់ល្អ ឬគ្មានការបង្ហាញឆន្ទះមិនពិត។

### ២.១.៣.១. បញ្ញត្តិស្តីការអនុវត្តដោយបង្ខំ

ទោះបីជា ភាគីនៃកិច្ចសន្យា បានធ្វើការបង្ហាញឆន្ទៈ ដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈភាពដែរ ប្រសិនបើ ខ្លឹមសារនៃកិច្ចសន្យាផ្ទុយពីបញ្ញត្តិស្តីពីការអនុវត្តដោយបង្ខំណាមួយ នោះវាត្រូវបានចាត់ទុកជាមោឃៈ[32]។ បញ្ញត្តិស្តីពីការអនុវត្តដោយបង្ខំ គឺសំដៅទៅលើបទប្បញ្ញត្តិដែលបដិសេធចំពោះអានុភាពនៃសកម្មភាពគតិយុត្តដែលធ្វើឡើងផ្ទុយនឹងបញ្ញត្តិនេះ។

ឧទាហរណ៍៖ **ក** បានចុះកិច្ចសន្យាទិញលក់នូវកាំភ្លើង ចំនួន៥ ដើមពី **ខ** ដោយ **ក** និង **ខ** បានបង្ហាញឆន្ទៈដោយស្ម័គ្រចិត្ត ដោយបានកំណត់អំពីប្រភេទ តម្លៃ ព្រមទាំងមានកាលបរិច្ឆេទច្បាស់លាស់នៅក្នុងកិច្ចសន្យាទៀតផង។ ទាក់ទងទៅនឹងកម្មវត្ថុនៃកិច្ចសន្យារវាង **ក** និង **ខ** ទោះបីជាភាគីទាំងពីរបង្កើតកិច្ចសន្យាដោយស្ម័គ្រចិត្តក៏ពិតមែន តែកាំភ្លើង ជាអាវុធដែលច្បាប់បានបញ្ញត្តិហាមឃាត់ក្នុងការទិញលក់ និងប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច។ ហេតុដូចនេះ កិច្ចសន្យាទិញលក់ខាងលើ ពុំអាចមានអានុភាពតាមផ្លូវច្បាប់នោះទេ ដោយសំអាងថាកម្មវត្ថុនៃកិច្ចសន្យាមានភាពផ្ទុយនឹងច្បាប់ ហើយកិច្ចសន្យាត្រូវមោឃៈ។

[32] មាត្រា ៣៥៤ ចំណុច ក នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

### ២.១.៣.២. សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ

ទំនៀមទំលាប់ ប្រពៃណី ព្រមទាំងសណ្តាប់ធ្នាប់សាធារណៈ ក៏ជាផ្នែកសំខាន់ផងដែរ ដែលប្រទេសនីមួយៗប្រកាន់យកមកអនុវត្ត ហើយចាត់ទុកបញ្ហាសណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់ ប្រពៃណីល្អ ជាកត្តាចាំបាច់ ដែលត្រូវអនុវត្តតាម។ ការបង្កើតកិច្ចសន្យាទាំងឡាយណា ដែលមានកម្មវត្ថុបានបំពានសណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់ល្អ ទោះបីជាភាគីបានបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យានោះត្រូវចាត់ទុកថាមោឃៈដែរ នេះដោយសំអាងថា កិច្ចសន្យាមានកម្មវត្ថុផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អរបស់ប្រទេស។ យ៉ាងណាមិញ ចំពោះអត្ថន័យនៃពាក្យសណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់ល្អនេះដែរ គឺពុំមានចែងច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណីឡើយ ដូច្នេះវាត្រូវបានសម្រេចដោយយុត្តិសាស្ត្ររបស់តុលាការ។

ឧទាហរណ៍៖ បុរស **ក** បានចុះកិច្ចសន្យាជាមួយនារី **ខ** ក្នុងគោលបំណងដើម្បីរួមភេទ ដោយផ្តល់នូវប្រាក់កម្រៃត្រលប់មកវិញ។ យ៉ាងណាមិញ កិច្ចសន្យារវាងបុរស និងនារីខាងលើ ត្រូវបានមោឃៈ ដោយសំអាងថា កម្មវត្ថុនៃកិច្ចសន្យា បានធ្វើឲ្យមានការប៉ះពាល់ដល់ទំនៀមទំលាប់ល្អរបស់ប្រទេសជាតិ ដែលផ្ទុយនឹងច្បាប់ ព្រមទាំងអាចបង្ករនូវភាពអសន្តិសុខ អសណ្តាប់ធ្នាប់ដល់សង្គម បើទោះបីជាមិនមានច្បាប់ហាមឃាត់ចំពោះកិច្ចសន្យាបែបនេះក៏ដោយ។

### ២.១.៣.៣. ការបង្ហាញឆន្ទៈមិនពិត

ដើម្បីបង្កើតកិច្ចសន្យា នោះភាគីនៃកិច្ចសន្យាត្រូវតែសំដែងឆន្ទៈត្រូវគ្នា ព្រមបង្កើត និងអនុវត្ត តាមគ្រប់ចំណុច ឬប្រការដែលមានចងភ្ជាប់ជាកាតព្វកិច្ចឲ្យភាគីនៃកិច្ចសន្យាគោរព និងធ្វើតាម។ លើសពីនេះទៅទៀត ក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិក្នុងមាត្រាមួយចំនួនថា ដើម្បីឱ្យកិច្ចសន្យាមួយ មានសុពលភាព លុះត្រាតែកិច្ចសន្យានោះ ធ្វើឡើងដោយការបង្ហាញឆន្ទៈគ្មានវិការៈ ពុំនោះទេ កិច្ចសន្យានឹងត្រូវបានលុបចោល។ ក្នុងក្រមនេះក៏បានបញ្ញត្តិផងដែរថា ការបង្ហាញឆន្ទៈមិនពិត ដែលធ្វើឡើងដោយឃុបឃិតជាមួយភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ[33]។ មូលហេតុដែលច្បាប់បញ្ញត្តិបែបនេះ ពីព្រោះតែចង់ការពារផលប្រយោជន៍ឱ្យ តតិយជន ដែលជាជនសុចរិតមិនបានដឹងពីការបង្ហាញឆន្ទៈមិនពិតរបស់ភាគីខាងលើនោះឡើយ បើតតិយជននេះបានដឹង ទំនងជាតតិយជននេះ មិនព្រមបង្កើតកិច្ចសន្យានេះឡើងដែរ។ ផ្ទុយទៅវិញ បើតតិយជននេះបានដឹងហើយតែនៅតែព្រមបង្កើតកិច្ចសន្យាបែបនេះឡើងទៀតនោះ កិច្ចសន្យាត្រូវចាត់ទុកថាមិនមានអានុភាព។

[33] មាត្រា ៣៥២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

## ២.២. លក្ខខណ្ឌទម្រង់

ជាគោលការណ៍ កិច្ចសន្យាត្រូវបង្កើតឡើងដោយសំណើ ត្រូវគ្នាជាមួយនឹងស្វីការ[34] ។ ដូច្នេះមានន័យថា កិច្ចសន្យាកើតឡើងដោយមិនចាំបាច់មានទម្រង់ជាក់លាក់នោះទេ បានសេចក្តីថាកិច្ចសន្យាបានបង្កើតឡើង ទោះបីជាបានធ្វើដោយផ្ទាល់មាត់ក៏ដោយ។

នៅក្នុងកិច្ចសន្យាអាណត្តិ ត្រូវបង្កើតដោយការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ[35] ។ មានន័យថាជាកិច្ចសន្យាដែលមានការព្រមព្រៀង ដែលមិនតម្រូវឱ្យធ្វើជាលាយលក្ខណ៍អក្សរសម្រាប់ជាល័ក្ខខ័ណ្ឌសុពលភាពនៃអាណត្តិនោះទេ។ ឱ្យតែមានឆន្ទៈត្រូវគ្នារវាងភាគីទាំងសងខាង នោះអាណត្តិនឹងត្រូវបានបង្កើតឡើង ឬ អាចនិយាយម្យ៉ាងទៀត នៅក្នុងករណីដែលអាណត្តិទាយកប្រគល់សិទ្ធិអំណាចឱ្យអាណត្តិគាហក ធ្វើកិច្ចការណាមួយ ហើយអាណត្តិគាហក ឯកភាពទទួលធ្វើកិច្ចសន្យានោះ នោះកិច្ចសន្យានឹងត្រូវបានបង្កើតឡើង។

ប៉ុន្តែនៅក្នុង ករណីដែលច្បាប់តម្រូវកិច្ចសន្យាត្រូវតែគោរពទៅតាមទម្រង់ជាក់លាក់ដែលច្បាប់កំណត់។ នៅក្នុងកិច្ចសន្យាណត្តិ ទោះបីជាច្បាប់មិនតម្រូវឱ្យធ្វើជាលិខិតឯកជន ឬលិខិតយថាភូតដើម្បីឱ្យកិច្ចសន្យាមានអានុភាពក៏ដោយ ក៏គូភាគីអាចព្រមព្រៀមគ្នាបង្កើតតាមឆន្ទៈត្រូវគ្នាបានដែរ។

### ២.២.១. លិខិតឯកជន

ការបង្កើតកិច្ចសន្យាអាណត្តិ ច្បាប់មិនតម្រូវឱ្យធ្វើជាលាយលក្ខណ៍អក្សរទេ មានន័យថា មិនតម្រូវជាលិខិតឯកជន ឬលិខិតយថាភូតទេ ដូចដែលបានរៀបរាប់ខាងលើហើយ តែគូភាគីអាចធ្វើក៏បាន ឬមិនធ្វើក៏បាន គឺអាស្រ័យទៅលើការយល់ព្រមរបស់គូភាគី។ ជាឧទាហរណ៍ ប្រសិនបើគូភាគីសម្រេចធ្វើជាលិខិឯកជន គឺអាចធ្វើបាន ក្នុងល័ក្ខខ័ណ្ឌនៃការបង្កើតកិច្ចសន្យា។

លិខិតឯកជន គឺជាលិខិតទាំងឡាយណា ដែលបង្កើតឡើងដោយបុគ្គលឯកជន ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ។ ចំពោះលិខិតប្រភេទនេះ គឺពិតជាងាយស្រួលក្នុងការធ្វើណាស់ ហើយងាយនឹងរងនៅហានិភ័យផងដែរ គឺងាយធ្វើឱ្យភាគីខាតប្រយោជន៍ មិនអាចតតាំងនឹងតតិយជនបាន ដោយសារតែកិច្ចសន្យាមិនទទួលស្គាល់អានុភាពដោយច្បាប់។ រវាងអាណត្តិទាយក និងអាណត្តិគាហក គឺគូភាគីអាចព្រមព្រៀងធ្វើបាន ទោះបីជាច្បាប់មិនតម្រូវក៏ដោយ ប៉ុន្តែដើម្បីជៀសវាងនៅការបាត់បងនៅផលប្រយោជន៍មួយចំនួន ឬដើម្បីជាល័ក្ខខ័ណ្ឌតតាំង គូភាគី គួរជ្រើសរើសធ្វើលិខិតយថាភូត។

[34] មាត្រា ៣៣៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[35] មាត្រា៦៣៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ២.២.២. លិខិតយថាភូត

លិខិតយថាភូត សំដៅលើ លិខិតដែលត្រូវធ្វើឡើងដោយសាការី ឬលិខិតឯកជនដែលសាការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់[36]។

កិច្ចសន្យាអាណត្តិ បើគូភាគីបានបង្កើតកិច្ចសន្យាពាក់ពន្ធនឹងរឿងអចនវត្ថុ គូភាគីគួរតែជ្រើសរើសយកការធ្វើជាលាយលក្ខណ៍អក្សរ និងជាលិខិតយថាភូត។

[36] មាត្រា ៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១

# ជំពូកទី ២

# កិច្ចសន្យាអាណត្តិ

## ផ្នែកទី ១ ប្រភេទនៃកិច្ចសន្យាអាណត្តិ

### ១.១. និយមន័យ

អាណត្តិ គឺជាកិច្ចសន្យា ដែលជនម្នាក់ឱ្យអំណាចទៅជនម្នាក់ទៀតឱ្យយកទៅ បំពេញកិច្ចការខ្លះក្នុងនាមខ្លួន និងតាំងខ្លួន[37]។ តាមអត្ថន័យនេះ យើងមិនដឹងថា ឃ្លាដែល ធ្វើក្នុងនាមខ្លួន និងតាំងខ្លួន ចង់សំដៅទៅលើអ្នកណាឱ្យប្រាកដទេ ហើយក៏មិនបានបញ្ជាក់ឱ្យច្បាស់លាស់អំពីទម្រង់នៃសកម្មភាពរបស់អាត្តិគាហកថា តើធ្វើក្នុងនាមអាណត្តិទាយក ឬក្នុងនាមអាណត្តិគាហកទេ។

នៅត្រង់ចំណុចនេះក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានឱ្យនិយមន័យច្បាស់លាស់ និងមិនធ្វើឱ្យយើងពិបាកយល់ថា តើអាណត្តិគាហកធ្វើក្នុងនាមនរណាឱ្យប្រាកដ?

កិច្ចសន្យាអាណត្តិ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអាណត្តិទាយក ប្រគល់សិទ្ធិអំណាចឱ្យភាគីម្ខាងទៀត ហៅថាអាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក។ នៅក្នុងន័យនេះ មិនបានកំណត់ជាក់លាក់ថាត្រូវតែ ធ្វើសកម្មភាពគតិយុត្តនោះទេ ដូច្នេះមានន័យថា ជាសកម្មភាពដែលរួមបញ្ចូលទាំងសកម្មភាពគតិយុត្ត ដូចជាការធ្វើកិច្ចសន្យា និងមិនមែនសកម្មភាពគតិយុត្ត ដូចជាការឱ្យធ្វើម្ហូបក្នុងរយៈពេលខ្លីជាដើម។

បើយើងមើលទៅកិច្ចសន្យាអាណត្តិ គឺជាកិច្ចសន្យាមួយដែលកើតចេញពីការទុកចិត្តគ្នាទៅវិញទៅមក ដោយសារតែអាណត្តិទាយក គាត់បានប្រគល់សិទ្ធិអំណាច និងកាតព្វកិច្ចទាំងស្រុង ជូនអាណត្តិគាហកឱ្យធ្វើកិច្ចការដើម្បីផលប្រយោជន៍ខ្លួន យ៉ាងទៀតបើយើងមើលទៅលើក្រមរដ្ឋប្បវេណី ជប៉ុន អាណត្តិ សំដៅលើការពឹងពាក់ ឱ្យនរណាម្នាក់ធ្វើអ្វីជំនួសខ្លួន ហើយអាស្រ័យទៅលើអ្នកពឹងពាក់ទាំងស្រុង ក្នុងការបំពេញករណីកិច្ចរបស់ខ្លួន ដោយយកចិត្តទុកដាក់ក្នុងឋានៈជាអ្នកគ្រប់គ្រងដោយសុចរិតត្រឹមត្រូវ និងករណីកិច្ចដោយប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងដោយសុចរិត[38] ។

ដោយសារតែការមានទំនាក់ទំនង និងការជឿទុកចិត្តគ្នា កិច្ចសន្យានេះមិនមានភាពស្មុគស្មាញ ក្នុងការបង្កើតនោះទេ ដោយគ្រាន់តែបង្កើតទៅតាមអត្ថន័យអាណត្តិ គឺគ្រប់គ្រាន់ហើយ។

[37] មាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ១៩៦៧

[38] មាត្រា ៦៤៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

### ១.២. លក្ខណៈទម្រង់នៃកិច្ចសន្យាអាណត្តិ

សម្រាប់ល័ក្ខខ័ណ្ឌទម្រង់ ជាល័ក្ខខ័ណ្ឌនៃការបង្កើតកិច្ចសន្យាដែលមិនមានការទាមទារនៅល័ក្ខខ័ណ្ឌអ្វីច្រើននោះទេ។ ប៉ុន្តែជាគោលកាណ៏នៃការបង្កើតកិច្ចសន្យានីមួយៗ គឺត្រូវតែមាននៅល័ក្ខខ័ណ្ឌដូចខាងលើ។ ដោយហេតុថា កិច្ចសន្យាអាណត្តិគឺជាកិច្ចសន្យាពិសេសមួយ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៅក្នុងចំណោមកិច្ចសន្យាពិសេសផ្សេងទៀត ដោយគ្រាន់តែមានការព្រមព្រៀងរវាងអាណត្តិទាយក និងអាណត្តិគាហកនោះកិច្ចសន្យាត្រូវបានកើតឡើង[39] ។

ប៉ុន្តែ ប្រសិនបើគូភាគីចង់បង្កើតកិច្ចសន្យាដូចល័ក្ខខ័ណ្ឌខាងលើនោះ គឺអាចធ្វើការបង្កើតបាន ពីព្រោះច្បាប់មិនបានចែងថា ត្រូវតែមានការព្រមព្រៀងជាល័ក្ខខ័ណ្ឌសុពលភាពនោះទេ។ ដូច្នេះ ការបង្កើតកិច្ចសន្យាអាណត្តិ គឺជាជម្រើសរបស់គូភាគី ថាចង់បង្កើតកិច្ចសន្យាអាណត្តិតាមរបៀបណា។ ជៀសវាងការមានវិវាទអាណត្តិទាយក និងអាណត្តិគាហក អាចធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ឬក៏ជាលិខិតយថាភូតក៏បាន។

មូលហេតុដែលច្បាប់បញ្ញត្តិថា កិច្ចសន្យាអាណត្តិត្រូវបង្កើតឡើងដោយការព្រមព្រៀងតែប៉ុណ្ណោះ គឺដោយសារតែ កិច្ចសន្យាអាណត្តិ ការទំនាក់ទង នឹងទុកចិត្តគ្នារវាងអាណត្តិទាយក និងអាណត្តិគាហកបានស្គាល់គ្នាតាំងពីយូរណាស់មកហើយ។ ឧទាហរណ៍ ប្រសិនបើនៅក្នុងសង្គមមួយបើមិនស្គាល់គ្នាច្បាស់ទេ នឹងមិនមានការទុកចិត្តលើគ្នាច្បាស់ទេ តើនឹងប្រគល់សិទ្ធិអំណាចរបស់ខ្លួនឱ្យទៅភាគីម្ខាងទៀតចាត់ចែងដោយរបៀបណា។ ម្យ៉ាងទៀតកិច្ចសន្យាអាណត្តិផ្អែកលើ គោលការស្វ័យភាពនៃបុគ្គលឯកជន រវាងអាណត្តិទាយក និងអាណត្តិគាហក ថាមិនយកកម្រៃ ឬយកកម្រៃ។

### ១.៣. កិច្ចសន្យាអាណត្តិដោយមិនយកកម្រៃ

ដោយសារតែកិច្ចសន្យាអាណត្តិកើតឡើងពីការទំនាក់ទំនងដោយទុកចិត្តរបស់អាណត្តិទាយក ទៅលើអាណត្តិគាហក ដើម្បីឱ្យធ្វើការចាត់ចែងកិច្ចការឱ្យខ្លួន ដូច្នេះភាគីអាចព្រមព្រមព្រៀងគ្នាថាបង្កើតកិច្ចសន្យាអាណត្តិដោយមិនយកកម្រៃ ឬ យកកម្រៃបាន[40]។

អ្នកដែលទទួលបានកម្រៃនៅក្នុងកិច្ចសន្យាអាណត្តិ គឺអាណត្តិគាហក ដោយខ្លួនទទួលពីថ្លៃសេវានៃការចាត់ចែងកិច្ចការអាណត្តិ ប៉ុន្តែបើអាណត្តិគាហក បានធ្វើការបង្ហាញឆន្ទៈថាខ្លួន ធ្វើកិច្ចសន្យានេះគឺមិនយកកម្រៃទេ ដូច្នេះអាណត្តិគាហកមិនទាមទារកម្រៃបានទេ មានន័យថា ការធ្វើកិច្ចសន្យាដែលមិនយកកម្រៃ គឺអាស្រ័យលើអាណត្តិគាហកព្រមព្រៀង នឹងអាណត្តិទាយកថាមិនយកកម្រៃនៅពេលដែលបង្កើតកិច្ចសន្យា។ ប៉ុន្តែ ក្រោយ

[39]សូមមើលមាត្រា ៦៣៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[40] មាត្រា ៦៣៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មក បើអាណត្តិគាហក គាត់នឹកឃើញថាចង់បានកម្រៃពីអាណត្តិទាយក ហើយគាត់បានទៅធ្វើការទាមទារពីអាណត្តិទាយក គឺពុំអាចធ្វើទៅបានឡើយ បើពុំបានកំណត់ពិសេសនៅក្នុងកិច្ចសន្យា[41]។

ឧទាហរណ៍៖ អាណត្តិទាយក បានប្រគល់សិទ្ធិអំណាចរបស់ខ្លួន ទៅឱ្យអាណត្តិគាហក ក្នុងការលក់អាវយឺតឱ្យខ្លួន នៅក្នុងការបង្កើតកិច្ចសន្យាបានកំណត់ថាមិនយកកម្រៃទេ។ បើទោះបីជាអាណត្តិគាហក បានលើកពីបញ្ហាអ្វី ដែលទាក់ទងនឹងសកម្មភាពខ្លួនក្នុងពេលដែលបំពេញអាណត្តិក៏ដោយ ក៏មិនអាចទាមទារបានដែរ។

**១.៤. កិច្ចសន្យាអាណត្តិដោយយកកម្រៃ**

អាណត្តិអាចទាមទារ យកកម្រៃបាន ក្នុងករណីដែលមានការព្រមព្រៀងគ្នា ថាយកកម្រៃ។ មានន័យថា អាណត្តិយកកម្រៃត្រូវមានអានុភាពភ្លាម នៅពេលដែលគ្រាន់តែមានការព្រមព្រៀង នោះវានឹងត្រូវបានកើតឡើង។ មិនត្រឹមតែក្នុងករណី ដែលមានការបង្ហាញឆន្ទៈដោយច្បាស់លាស់អំពីការអាណត្តិដោយយកកម្រៃប៉ុណ្ណោះទេ ព្រមទាំងក្នុងករណីដែលមិនមានការបង្ហាញឆន្ទៈ ច្បាស់លាស់ តែមានការព្រមព្រៀងដោយតុណ្ហីភាព ក៏អាណត្តិនេះ ក៏ត្រូវបានគេបកស្រាយថាជាអាណត្តិយកកម្រៃដែរ។ ដូច្នេះប្រសិនបើមានការបញ្ជាក់ថាភាគីទាំងពីរមានការព្រមព្រៀងគ្នាដើម្បីធ្វើអាណត្តិដោយយកកម្រៃ ទោះបីជាដោយជាក់លាក់ ឬដោយតុណ្ហីភាពក៏ដោយ ក៏ការសន្មត់ថាជាអាណត្តិដោយមិនយកកម្រៃត្រូវបានបដិសេធដែរ ហើយអាចត្រូវបានបកស្រាយថាជាអាណត្តិយកកម្រៃ។

ការបង្ហាញឆន្ទៈ ថាយកកម្រៃ អាចធ្វើឡើងដោយជាក់លាក់ ដោយតុណ្ហីភាព ដោយលាយលក្ខអក្សរ ឬដោយផ្ទាល់មាត់នៅពេលដែលបង្កើតកិច្ចសន្យាអាណត្តិ។

ឧទាហរណ៍ៈ លោក **ក** នៅសៀមរាប ដោយសារតែរវល់នឹងការងារច្រើនពេក ខ្លួនបានបង្កើតកិច្ចសន្យាអាណត្តិជាមួយលោក **ខ** ដោយឱ្យលោក **ខ** រកទិញដីមួយកន្លែងនៅភ្នំពេញឱ្យខ្លួនដើម្បីបើកហាងអាហារ។ ស្របពេលនោះ ខ្លួនមានការសប្បាយចិត្តជាខ្លាំងថា នឹងទទួលបានកម្រៃពីកិច្ចសន្យានេះដើម្បីជួយសម្រួលដល់ជីវភាពគ្រួសារ ហើយខ្លួនបានប្រាប់ទៅលោក **ក** ខ្លួនសុំទារទាមសេវាពីកិច្ចសន្យានេះ នៅពេលនោះ **ក** មិនបានឆ្លើយតបអ្វីទាំងអស់។ នៅពេលដែលកិច្ចសន្យាត្រូវបានបញ្ចប់ លោក **ខ** ដែលជាអាណត្តិគាហក បានធ្វើការទាមទារពី លោក **ក** ដែលជាអាណត្តិទាយក ឱ្យផ្តល់កម្រៃឱ្យខ្លួន ក្នុងករណីនេះ គឺ **ក** ត្រូវតែផ្តល់កម្រៃឱ្យ **ខ** ទោះបីជាមិនការព្រមព្រៀងជាក់លាក់ក៏ដោយ។

[41] សូមមើលមាត្រា ៦៤៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ផ្នែកទី ២ សិទ្ធិ និងកាតព្វកិច្ចរបស់អាណត្តិទាយក និង អាណត្តិគាហក

នៅពេលដែលកិច្ចសន្យា ត្រូវបានបង្កើតឡើង នោះសិទ្ធិ និងកាតព្វកិច្ច ត្រូវបានបង្កើតឡើងចំពោះកិច្ចសន្យាអាណត្តិ ហើយវាក៏មិនខុសពីកិច្ចសន្យាដទៃដែរ នៅពេលដែលកិច្ចសន្យាត្រូវបានបង្កើតឡើងគឺ អាណត្តិទាយក និងអាណត្តិគាហក ត្រូវមានសិទ្ធិ និងកាតព្វកិច្ចអនុវត្តរៀងៗខ្លួន ហើយក៏ត្រូវមានទំនួលខុសត្រូវរៀងៗខ្លួនដែរ។

### ២.១. សិទ្ធិ និងកាតព្វកិច្ចរបស់អាណត្តិទាយក

#### ២.១.១. សិទ្ធិរបស់អាណត្តិទាយក

- ✓ សិទ្ធិទាមទារឱ្យអាណត្តិគាហក រាយការណ៍អំពីស្ថានភាពនៃកិច្ចការចាត់ចែងអាណត្តិ ទោះបីនៅពេលណាក៏ដោយ ក៏ត្រូវរាយការណ៍ដោយគ្មានការយឺតយ៉ាវ
- ✓ សិទ្ធិទាមទារសំណងការខូចខាត ពីអាណត្តិគាហក ក្នុងករណីដែលអាណត្តិគាហកមិនប្រុងប្រយ័ត្ននៅពេលដែលចាត់ចែងកិច្ចការអាណត្តិ
- ✓ សិទ្ធិទាមទារឱ្យប្រគល់ប្រាក់ និងវត្ថុផ្សេងៗទៀតដែលអាណត្តិគាហកទទួលបានក្នុងពេលចាត់ចែងកិច្ចការអាណត្តិ
- ✓ សិទ្ធិទាមទារ ឱ្យសងការប្រាក់ ក្នុងករណីដែលអាណត្តិគាហកបានប្រើប្រាក់ ដែលត្រូវប្រគល់មកឱ្យខ្លួន ឬបានប្រើប្រាក់ដែលទុកសម្រាប់កិច្ចការអាណត្តិ។

#### ២.១.២. កាតព្វកិច្ចរបស់អាណត្តិទាយក

##### ២.១.២.១. ករណីយកិច្ចបង់កម្រៃ

អាណត្តិគាហក ពុំអាចទាមទារកម្រៃចំពោះអាណត្តិទាយកបានឡើយ ក្នុងករណីដែលពុំបានកំណត់ជាពិសេស នៅក្នុងកិច្ចសន្យា[42] ។ បើគ្មានការកំណត់ពិសេស ដែលត្រូវឱ្យអាណត្តិទាយក បងកម្រៃឱ្យអាណត្តិគា-ហកនោះទេ នាំឱ្យអាណត្តិគាហកពុំអាចទាមទារបានឡើយ ព្រោះថា ជាគោលការណ៍កិច្ចសន្យាអាណត្តិមិនយកកម្រៃ។ ដូច្នេះ ប្រសិនបើអាណត្តិគាហកចង់យកកម្រៃតាមរយៈកិច្ចសន្យាអាណត្តិ នោះអាណត្តិគាហក ត្រូវបង្កើតកិច្ចព្រមព្រៀងពិសេស ឬការចរចារផ្សេងៗមុននឹងបង្កើតកិច្ចសន្យាអាណត្តិនោះ។

នៅក្នុងករណីនៃអាណត្តិដោយយកកម្រៃ អាណត្តិគាហកមិនអាចទាមទារកម្រៃបានឡើយ បើមិនបានបញ្ចប់ការអនុវត្តករណីយកិច្ចដែលត្រូវតាមអាណត្តិនោះរួចហើយទេ។ ប៉ុន្តែ បើបានកំណត់កម្រៃតាមអំឡុងពេលអាចទាមទារបាន នៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត[43] ។ ជាទូទៅនៅក្នុងករណីដែលអាណត្តិ

---

[42] មាត្រា៦៤៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[43] មាត្រា៦៤៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

យកកម្រៃ អាណត្តិទាយកមិនចាំបាច់បង់កម្រៃមុនការអនុវត្តទេ មានន័យថា អាណត្តិទាយក អាចបង់កម្រៃ នៅក្រោយពេលបញ្ចប់ការងារក៏បាន។ ប៉ុន្តែ បើមានការ ព្រមព្រៀងផ្សេងពីនេះ ដូចជា ការកំណត់រយៈពេលក្នុងការបង់កម្រៃ នោះពេលផុតរយៈពេលនោះ អាណត្តិទាយកត្រូវបង់កម្រៃទៅអាណត្តិគាហកតាមការព្រមព្រៀង។

បើអាណត្តិត្រូវបានបញ្ចប់ការអនុវត្ត នៅពាក់កណ្ដាលទីដោយសារមូលហេតុដែលមិនមែនជាការទទួលខុសត្រូវរបស់អាណត្តិគាហក អាណត្តិគាហកអាចទាមទារកម្រៃបាន តាមសមាមាត្រនៃភាគរយដែលបានអនុវត្តរួចហើយនោះ[44]។ នេះបង្ហាញថា ប្រសិនបើអាណត្តិត្រូវបានបញ្ចប់អាណត្តិនៅពាក់កណ្ដាលទី ដែលមិនមែនជាកំហុសរបស់អាណត្តិគាហក នាំអោយអាណត្តិគាហក អាចទាមទារកម្រៃបាន តាមសមាមាត្រដែលបានអនុវត្តរួច ព្រោះថាគោលបំណងរបស់អាណត្តិគឺ មិនមែនសម្រេចការងារដែលបានកំណត់ ដែលតម្រូវជាដាច់ខាតដូចកិច្ចសន្យាម៉ៅការនោះទេ។

### ២.១.២.២. ករណីកិច្ចបង់សោហ៊ុយជាមុន

ប្រសិនបើ មានតម្រូវការចាំបាច់លើសោហ៊ុយសម្រាប់ចាត់ចែងកិច្ចការអាណត្តិ អាណត្តិទាយក ត្រូវបង់សោហ៊ុយនោះជាមុន តាមការទាមទាររបស់អាណត្តិគាហក[45] ។

ករណីកិច្ចរបស់អាណត្តិទាយក ក្នុងការបង់សោហ៊ុយ គឺមានគោលបំណងចង់ឱ្យ ការចាត់ចែងកិច្ចការអាណត្តិ ដំណើរការប្រព្រឹត្តិទៅប្រកបដោយភាពរលូន។ ម្យ៉ាងទៀត ទោះបីជាកិច្ចសន្យាអាណត្តិ ជាកិច្ចសន្យាដែលយកកម្រៃ ឬមិនយកកម្រៃក៏ដោយ ក៏អាណត្តិគាហកនៅតែអាចទាមទារកម្រៃជាមុនបាន ព្រោះថាកិច្ចសន្យាអាណត្តិនោះ នឹងចំណាយធនធានខ្លះ សម្រាប់បំពេញកិច្ចការអាណត្តិនោះ ឬ មួយអាចនិយាយម្យ៉ាងទៀតថា អាណត្តិគាហក យកធនធានរបស់អាណត្តិទាយក ទៅបម្រើផលប្រយោជន៍ឱ្យអាណត្តិទាយក មិនមែនយកធនធានរបស់ខ្លួនទៅបម្រើផលប្រយោជន៍ឱ្យអ្នកផ្សេងឡើយ ដែលនេះ គឺជាគោលការណ៍សមធម៌សម្រាប់ការពារភាគីទាំងសងខាង នៅក្នុងកិច្ចសន្យាអាណត្តិ។

### ២.១.២.៣. ករណីយកិច្ចសងវិញនូវសោហ៊ុយដែលបានចំណាយ

ដោយយោងទៅតាមមាត្រា ៦៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ អាណត្តិគាហកអាចទាមទារសោហ៊ុយពីអាណត្តិទាយកជាមុនបាន។

ផ្ទុយមកវិញបើយោងទៅតាមស្មារតី នៃមាត្រា ៦៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានសំដៅថា បើទោះបីជាអាណត្តិគាហក មិនបានស្នើសុំឱ្យអាណត្តិទាយក បង់សោហ៊ុយជាមុននោះទេ ប៉ុន្តែអាណត្តិគាហកមានសិទ្ធិទាមទារនូវសោហ៊ុយដែលបានចំណាយ និង ការប្រាក់ពី អាណត្តិទាយកបានដែរ ប្រសិនបើអាណត្តិគា

---

[44] មាត្រា៦៤៤ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[45] មាត្រា៦៤៥ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២២០៧

ហាកបានប្រើទ្រព្យសម្បត្តិផ្ទាល់ខ្លួនសម្រាប់ចាត់ចែង កិច្ចការអាណត្តិ ដែលជាប្រយោជន៍របស់អាណត្តិទាយក នោះ។

ជាមួយគ្នានេះដែរ ប្រសិនបើ អាណត្តិគាហកបានអនុវត្តកាតព្វកិច្ចចាំបាច់ដើម្បីចាត់ចែងកិច្ចការអាណត្តិ នោះអាណត្តិគាហកអាចទាមទារអោយអាណត្តិទាយកសងនូវកាតព្វកិច្ចនោះជំនួសខ្លួនបាន។ បើទោះបីជាអាណត្តិទាយកគ្មានកំហុសក៏ដោយ ក៏ត្រូវតែទទួលខុសត្រូវដែរ ដែលមានន័យថា មិនចាំបាច់មានកំហុសរបស់អាណត្តិទាយក ទើបអាចទាមទារអោយអាណត្តិទាយកទទួលខុសត្រូវនោះទេ។

ទន្ទឹមនឹងនេះដែរ បើយោងតាមមាត្រា ៦៤៦ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ប្រសិនបើមានការខូចខាត កើតឡើង តែមិនមែនជាកំហុសរបស់អាណត្តិគាហក នោះអាណត្តិគាហកអាចទាមទារសំណងនៃ ការខូចខាតពីអាណត្តិទាយកបាន។ នេះគឺជាការទទួលខុសត្រូវជាដាច់ខាតរបស់អាណត្តិទាយក ព្រោះ អាណត្តិទាយកគឺជាអ្នកដែលទទួលរងនូវហានិភ័យនេះ។ ប៉ុន្តែ ប្រសិនបើការកើតឡើងនូវការខូចខាតជាកំហុសរបស់តតិយជនណាមួយនោះ នោះអាណត្តិគាហកអាចទាមទារសំណងពីអាណត្តិទាយកបាន ដែលកំរិតត្រឹមតែលទ្ធភាពនៃសំណង ពី តតិយជនតែប៉ុណ្ណោះ។

### ២.១.២.៤. ករណីយកិច្ចសងសំណងនៃការខូចខាត

ដោយផ្អែកលើ មាត្រា ៦៤៦ កថាខណ្ឌទី ៣ ប្រសិនបើ បានទទួលការខូចខាត ដែលមិនមែនបណ្តាលមកពីកំហុសរបស់ខ្លួន (អាណត្តិគាហក) ក្នុងការចាត់ចែងកិច្ចការអាណត្តិ នោះ អាណត្តិគាហក អាចទាមទារសំណងនៃការខូចខាត ពីអាណត្តិទាយកបាន ។ នេះគឺជាការទទួលខុសត្រូវជាដាច់ខាតរបស់ អាណត្តិទាយក។ អាណត្តិទាយក ត្រូវតែទទួលបន្ទុកហានិភ័យនៃអាណត្តិ។ ក៏ប៉ុន្តែ ប្រសិនបើ ការខូចខាតនោះ កើតឡើងដោយចេតនា ឬ កំហុសរបស់ តតិយជន ពេលនោះ អាណត្តិគាហក អាចទាមទារសំណងចំពោះអាណត្តិទាយកបាន ត្រឹមតែកម្រិត ដែល អាណត្តិគាហក មិនបានទទួលពីតតិយជនតែប៉ុណ្ណោះ ។

ឧទាហរណ៍៖ **ក** បានផ្តល់អាណត្តិអោយទៅ **ខ** ដើម្បីមើលថែរក្សាកូនរបស់ **ក** ហើយ ឆ្កែដែលគ្មានម្ចាស់បានមកខាំក្មេងនោះ ហើយគាត់បានព្យាយាមការពារក្មេងនោះហើយដែលបានធ្វើអោយគាត់រងរបួស ។

ប្រសិនបើការខូចខាតបណ្តាលពីកំហុសរបស់តតិយជននោះ **ខ** ទាមទារសំណងពី **ក** ត្រឹមកំរិតដែល **ក** មិនបានទទួលសំណងពីតតិយជននោះ។ ដូច្នេះ ឧទាហរណ៍៖ ប្រសិនបើ **គ** បានបង្កោឆ្កែឱ្យខាំកូនរបស់ **ក** នាំអោយ **ខ** រងរបួស។ សោហ៊ុយព្យាបាលលើរបួសនេះ អស់ ១០០ ដុល្លា។ ក៏ប៉ុន្តែ **គ** បានបង់អោយ **ខ** តែ ២០ ដុល្លាទេ។ ក្នុងករណីនេះ ខ អាចទាមទារពី **ក** ៨០ ដុល្លា បន្ថែមទៀត ព្រោះថា **ខ** បានរងរបួសដោយសារកិច្ចការពារអាណត្តិចំពោះ **ក** ។

### ២.២. សិទ្ធិ និងភាតព្វកិច្ចរបស់អាណត្តិគាហក

#### ២.២.១. សិទ្ធិរបស់អាណត្តិគាហក

##### ២.២.១.១. សិទ្ធិទាមទារកម្រៃរបស់អាណត្តិគាហក

អាណត្តិគាហក ពុំមានសិទ្ធិទាមទារកម្រៃ ចំពោះអាណត្តិទាយកបានឡើយ ក្នុងករណីដែលពុំបានកំណត់ពិសេសក្នុងកិច្ចសន្យា ប៉ុន្តែចំពោះកិច្ចសន្យាដែលមិនយកកម្រៃ តើអាណត្តិគាហកអាចទាមទារកម្រៃ ពីអាណត្តិទាយកបានដែរឬទេ?

**ក. ករណីអាណត្តិយកកម្រៃ**

ការកំណត់ថា យកកម្រៃគឺមានការព្រមព្រៀងរបស់គូភាគីថាយកកម្រៃ ឬមិនយកកម្រៃដូចដែលបានបង្ហាញខាងដើមហើយ។ ក្នុងកិច្ចសន្យាអាណត្តិ ដោយយកកម្រៃ ប្រសិនបើ អាណត្តិត្រូវបានបញ្ចប់នៅពាក់កណ្តាលទី ដោយសារមូលហេតុដែលមិនមែន ជាការទទួលខុសត្រូវរបស់អាណត្តិគាហក នោះអាណត្តិគាហក អាចទាមទារកម្រៃបានតាមសមាមាត្រនៃភាគដែលបានអនុវត្តរួចហើយ[46]។

បើធៀបទៅនឹងកិច្ចសន្យាម៉ៅការ អ្នកម៉ៅការមានករណីយកិច្ចសម្រេចការងារ (កាតព្វកិច្ចសម្រេចលទ្ធផល) ហើយ ប្រសិនបើកិច្ចសន្យាត្រូវបានបញ្ចប់នៅពាក់កណ្តាលទី ដោយមិនបានសម្រេចការងារ នោះអ្នកម៉ៅការទទួលបន្ទុកនូវហានិភ័យនេះ (មានន័យថា អ្នកម៉ៅការ មិនអាចទាមទារកម្រៃពីម្ចាស់ការបានឡើយ)។ ចំពោះករណី កិច្ចសន្យាអាណត្តិវិញ ដោយសារអាណត្តិគាហកមានករណីយកិច្ចចាត់ចែងកិច្ចការអាណត្តិ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់ គ្រងសុចរិត ដោយផ្អែកតាមអត្ថន័យនៃអាណត្តិ ប៉ុន្តែ មិនមានករណីយកិច្ចសម្រេចកិច្ចការអាណត្តិឱ្យចប់សព្វគ្រប់ទេ (កាតព្វកិច្ចផ្តល់មធ្យោបាយ) ទោះបីជាកិច្ចការអាណត្តិ ត្រូវបានបញ្ចប់នៅពាក់កណ្តាលទីក៏ដោយ ក៏អាណត្តិគាហកមាន សិទ្ធិទាមទារកម្រៃក្នុងទំហំសមរម្យដែរ។ ចំពោះបញ្ហាដែលបញ្ចប់អាណត្តិនៅពាក់កណ្តាលទី គឺអាណត្តិគាហក គាត់ធ្វើការទាមទារបាន បើការបញ្ចប់នោះ មិនមែនមកពីមូលហេតុរបស់គាត់។

នៅក្នុងកិច្ចសន្យាអាណត្តិ ដែលយកកម្រៃ ជាគោលការណ៍នៅពេលដែលអាណត្តិគាហកអនុវត្តនៅកាតព្វកិច្ចរបស់ខ្លួនចប់ ទើបខ្លួនមានសិទ្ធិទាមទារកម្រៃ។ ប៉ុន្តែនៅក្នុងករណីពិសេស ដែលអាណត្តិត្រូវបានបញ្ចប់ដូចករណីខាងលើ គឺអាណត្តិទាយកអាចទាមទារបាន។ ក្រៅពីករណីនេះ ក៏អាណត្តិគាហកអាចទាមទារកម្រៃបានដែរ បើគូភាគីបានព្រមព្រៀងគ្នាពិសេស ទោះបីជាអាណត្តិ គាហកមិនបានអនុវត្តកាតព្វកិច្ចចប់ក៏

[46] មាត្រា៦៤៩ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដោយ ក៏ខ្លួនអាចទាមទារកម្រៃបានដែរ ក្នុងករណីដែលបាន កំណត់ កម្រៃតាមអំឡុងពេល ហើយខ្លួនអាចទាមទារបាន នៅក្រោយពេលដែល អំឡុងពេលនោះបានកន្លងផុត[47] ។

## ខ. ករណីអាណត្តិដែលមិនយកកម្រៃ

ការបង្កើតកិច្ចសន្យាអាណត្តិ មិនយកកម្រៃ គឺជាឆន្ទៈរបស់គូភាគី ថាព្រមព្រៀងគ្នាមិនយកកម្រៃ ហើយពាក្យថា ព្រៀមព្រៀងគ្នា គឺមានន័យថាភាគីទាំងសងខាងបានដឹង និងបានយល់ស្របគ្នាទាំងសងខាង ហើយស្របទៅតាមបញ្ញត្តិច្បាប់ដែលបានកំណត់ដែរ ត្រង់មាត្រា ៦៤៤ ត្រង់ចំណុចទី ១ នៃក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ ២០០៧ អាណត្តិគាហក ពុំអាចទាមទារកម្រៃចំពោះអាណត្តិទាយកបានឡើយ ក្នុងករណីដែលពុំបានកំណត់ពិសេស ក្នុងកិច្ចសន្យា។ មានន័យថា ទាល់តែបានកំណត់នៅក្នុងកិច្ចសន្យានៅពេលដែលបានបង្កើតអាណត្តិ ឬមួយក៏ភាគីបានព្រមព្រៀងគ្នាអំពីរឿងនេះ។

ចុះបើក្នុងករណី ដែលអាណត្តិ យកកម្រៃ តែត្រូវធ្វើឡើងដោយគុណ្ឋិភាព តើអាណត្តិគាហក អាចទាមទារកម្រៃបានដែរ ឬទេ ក្នុងករណីដែលអាណត្តិត្រូវបានបញ្ចប់នៅពាក់កណ្តាលទី?

សិទ្ធិរបស់អាណត្តិគាហក គឺគាត់អាចទាមទារបាន ក្នុងករណីដែលដែលបានកំណត់ជាក់លាក់ ឬ ក៏មានការព្រមព្រៀងគ្នា ប៉ុន្តែបើមិនផ្តល់សិទ្ធិឱ្យអាណត្តិគាហកទាមទារកម្រៃត្រង់កន្លែងនេះ គឺមិនសមហេតុផលទេសម្រាប់គាត់ ដោយសារតែ គាត់បានគោរពនៅកាតព្វកិច្ច ប្រុងប្រយ័ត្នដូចក្នុងន័យអាណត្តិ ដូច្នេះត្រង់ចំណុចនេះ គួតែផ្តល់សិទ្ធិឱ្យគាត់។

## ២.២.១.២. សិទ្ធិទាមទារឱ្យសងមកវិញនូវសោហ៊ុយ ដែលខ្លួនបានចំណាយ

ទោះបីជា អាណត្តិដោយយកកម្រៃ ឬមិនយកកម្រៃក៏ដោយ ក៏អាណត្តិគាហកមានសិទ្ធិទាមទារសោហ៊ុយដែលខ្លួនបានចំណាយដែរ ប្រសិនបើបានចំណាយប្រាក់ដែលទទួលស្គាល់ថាចាំបាច់សម្រាប់ធ្វើការចាត់ចែងកិច្ចការអាណត្តិ អាណត្តិគាហកអាចទាមទារចំពោះអាណត្តិទាយកឱ្យ សងមកវិញ នូវសោហ៊ុយ និងការប្រាក់បាន ដោយគិតចាប់ពីក្រោយថ្ងៃដែលបានចំណាយសោហ៊ុយនោះ[48]។

ប្រសិនបើ បានទទួលបន្ទុកកាតព្វកិច្ចដែលទទួលស្គាល់ថា ចាំបាច់សម្រាប់ធ្វើការចាត់ចែងកិច្ចការអាណត្តិ អាណត្តិគាហកអាចឱ្យ អាណត្តិទាយកសងកាតព្វកិច្ចនោះជំនួសខ្លួន ឬបើពុំទាន់ដល់កំណត់ពេលដែលត្រូវសងកាតព្វកិច្ចនោះទេ អាចឱ្យដាក់ ប្រាតិភោគដែលសមរម្យបាន[49]។ ប្រសិនបើ បានទទួលការខូចដែល

[47] មាត្រា៦៤៤ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[48] មាត្រា៦៤៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[49] មាត្រា៦៤៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មិនមែនបណ្តាលមកពីកំហុសរបស់ខ្លួន នៅក្នុងការចាត់ចែងកិច្ចការអាណត្តិទេ អាណត្តិគាហកអាចទាមទារសំណងនោះ ពីអាណត្តិទាយកបាន[50] ។

### ២.២.២. កាតព្វកិច្ច របស់អាណត្តិគាហក

#### ២.២.២.១. ករណីកិច្ចប្រុងប្រយ័ត្ន

អាណត្តិគាហក មានករណីកិច្ចចាត់ចែងកិច្ចការអាណត្តិ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ដោយផ្អែកតាមអត្ថន័យនៃអាណត្តិ[51] ។

កម្រិតនៃទំហំ ឬករណីកិច្ចនេះ ត្រូវបានសម្រេចដោយធ្វើការពិចារណាទៅលើអ្វី ដែលជននៅក្នុងឋានៈនេះត្រូវយកចិត្តទុកដាក់ដោយវិធីណា ជាទូទៅ។ ឧទាហរណ៍ បុគ្គលដែលមានជំនាញនិងចំណេះដឹងខ្ពស់ ដូចជាគ្រូពេទ្យ ត្រូវមានករណីកិច្ចខ្ពស់ក្នុងការចាត់ចែងកិច្ចការ។ ផ្ទុយទៅវិញកម្រិតស្តង់ដានៃករណីកិច្ចប្រុងប្រយ័ត្នរបស់បុគ្គល ដែលស្ម័គ្រចិត្តក្នុងមើលថែកូនអ្នកជិតខាង គឺត្រូវមានតិចជាងអ្នកជំនាញ។ ទទឹមនឹងនេះ កម្រិត ឬលំដាប់នៃកាតព្វកិច្ចប្រុងប្រយ័ត្ននេះ កើតមានមិនថា អាណត្តិដោយយកកម្រៃ ឬអាណត្តិមិនយកកម្រៃទេ ដោយសារអាណត្តិ ត្រូវបានបង្កើតឡើងដោយឈរលើគោលការណ៍ជឿ ទុកចិត្ត រវាងភាគីអាណត្តិទាយក និងអាណត្តិគាហក។ ប៉ុន្តែ កម្រិតនៃករណីកិច្ចនេះអាចត្រូវបានបន្ថយអាស្រ័យទៅតាមការព្រមព្រៀងរបស់ភាគី[52]។

ក្នុងករណីដែលអាណត្តិគាហក ធ្វើផ្ទុយនឹងករណីកិច្ចប្រុងប្រយ័ត្ន ហើយបានធ្វើមានការខូចខាតដល់អាណត្តិទាយក អាណត្តិទាយកអាចទាមទារសំណងនៃការខូចខាតនោះពីអាណត្តិគាហកបាន។ នៅក្នុងករណីនេះប្រសិនបើជាអាណត្តិដោយមិនយកកម្រៃ តុលាការអាចបន្ថយចំនួនទឹកប្រាក់សំណងនៃការខូចខាតបាន[53]។ មានន័យថាអាណត្តិគាហកត្រូវទទួលខុសត្រូវ ដោយយោងតាមគោលការណ៍ទូទៅ អំពីការមិនអនុវត្តកាតព្វកិច្ចដែលតម្រូវឲ្យភាគីបង្កព្យសនកម្មម្ខាងទៀត ត្រូវបង់នូវសំណងខូចខាត នៅក្នុងករណីនៃការបំពាននោះបង្កជាការខូចខាតមកពីការមិនគោរពខសន្យា។ នៅក្នុងករណីនេះអាណត្តិទាយកអាចទាមទារឱ្យរំលាយកិច្ចសន្យា និង/ឬសំណងនៃការខូចខាត។ ប៉ុន្តែបើជា អាណត្តិដែលមិនយកកម្រៃនោះ នោះតុលាការ អាចបន្ថយចំនួនទឹកប្រាក់សំណងការខូចខាត ព្រោះអាណត្តិគាហកមិនទទួលផលប្រយោជន៍អ្វីពីកិច្ចសន្យាអាណត្តិនោះទេ។

[50] មាត្រា៦៤៦ កថាខណ្ឌទី ៣ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[51] មាត្រា៦៤០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[52] មាត្រា៦៤០ កថាខណ្ឌទី ១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[53] មាត្រា៦៤០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ២.២.២.២. ករណីកិច្ចរាយការណ៍

បើមានការទាមទាររបស់អាណត្តិទាយក អាណត្តិគាហក ត្រូវរាយការអំពីស្ថានភាពនៃកិច្ចការចាត់ចែងអាណត្តិ ទោះបីនៅពេលណាក៏ដោយ[54] ។

ករណីនេះ គឺទាញចេញពីករណីកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ។ វាមានសារៈសំខាន់ណាស់សម្រាប់អាណត្តិគាហក ក្នុងការដឹងអំពីដំណើរការនៃកិច្ចការរបស់ខ្លួនដល់កម្រិតណាហើយ ដូច្នេះគាត់អាចឆ្លើយតបទៅនឹងបញ្ហានេះ។

តើអាណត្តិគាហក ត្រូវរាយការណ៍ពីស្ថានភាពដែរឬទេ បើទោះបីជាអាណត្តិទាយកមិនបានស្នើសុំក៏ដោយ? ទោះបីជាអាណត្តិទាយក មិនបានស្នើសុំឱ្យរាយការណ៍ក៏ដោយ គេអាចចាត់ទុកថា អាណត្តិគាហកត្រូវរាយការណ៍អំពីស្ថានភាពបច្ចុប្បន្ន នៃការចាត់ចែងនោះ នៅពេលដែលមានភាពចាំបាច់សម្រាប់ទាយក។

ផលវិបាកនៅក្នុងករណីដែលអាណត្តិគាហកបំពានករណីកិច្ចនេះ ពីព្រោះតែការរាយការណ៍ ជាករណីកិច្ចតាមផ្លូវច្បាប់ យោងតាមគោលការណ៍ទូទៅអំពីការមិនអនុត្តកាតព្វកិច្ច នោះអាណត្តិទាយកអាចរំលាយកិច្ចសន្យា ហើយគាត់អាចទាមទារសំណងនៅក្នុងករណីដែលមានការខូចខាតកើតមានឡើង។

មាត្រា ៦៤៥ នៃក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ ១៩៩២ នៅពេលណាមួយ ដែលមានការស្នើសុំដោយអ្នកប្រគល់អាណត្តិ អាណត្តិគហាក ត្រូវធ្វើរបាយការណ៍ ស្តីពីល័ក្ខខ័ណ្ឌ នៃការគ្រប់គ្រងការងារ ដែលបានប្រគល់មកឱ្យគេ និង នៅពេលដែលបញ្ចប់អាណត្តិ គេត្រូវធ្វើរបាយការណ៍ពេញលេញ ដោយមិនមានការយឺតយ៉ាវ[55]។

### ២.២.២.៣. ភាតព្វកិច្ចប្រគល់

អាណត្តិគាហកត្រូវប្រគល់ប្រាក់ និងវត្ថុផ្សេងៗទៀតដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិឱ្យទៅអាណត្តិទាយក។ អាណត្តិគាហកក៏ត្រូវប្រគល់ផលដែលប្រមូលបានឱ្យទៅអាណត្តិទាយកផងដែរ[56] ។

សិទ្ធិដែលអាណត្តិគាហកបានលទ្ធកម្មនៅក្នុងនាមរបស់ខ្លួន ដើម្បីអាណត្តិទាយកត្រូវផ្ទេរសិទ្ធិនោះឱ្យទៅអាណត្តិទាយក។

មាត្រា ៦៤៦ នៃក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ ១៩៩២ អាណត្តិគាហក ត្រូវប្រគល់ទៅឱ្យ អ្នកប្រគល់អាណត្តិ នូវប្រាក់ និងរបស់ទាំងអស់ ដែលគេបានទទួលនៅក្នុងការគ្រប់គ្រងការងារ ដែលប្រគល់មកអោយគេនោះ ហើយត្រូវអនុវត្តដូចគ្នា ចំពោះផលិតផល ដែលគេប្រមូលបាន។

[54] មាត្រា៦៤១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[55] មាត្រា៦៤៥ នៃក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ ១៩៩២

[56] មាត្រា៦៤២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សិទ្ធិទាំងអស់ ដែលអាណត្តិគាហក ទទួលបានក្នុងនាមរបស់គេ តាមនាមអ្នកប្រគល់អាណត្តិ ត្រូវបាន ផ្ទេរទៅអោយអ្នកប្រគល់អាណត្តិ[57]។

នេះក៏ដោយសារ អាណត្តិទាយកប្រគល់សិទ្ធិអំណាចឱ្យអាណត្តិគាហក ចាត់ចែងការងារដើម្បីផល ប្រយោជន៍ខ្លួន ដូចនេះនៅពេលដែលអាណត្តិគាហកបញ្ចប់ការងារ គាត់ត្រូវប្រគល់ប្រាក់ និងវត្ថុផ្សេងៗទៀត ដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិឱ្យទៅអាណត្តិទាយក។ លើសពីនេះ អាណត្តិគាហកក៏ត្រូវ ប្រគល់ផលដែលប្រមូលបានឱ្យទៅអាណត្តិទាយកផងដែរ។

ឧទាហរណ៍៖ នៅក្នុងករណីដែល A បានផ្តល់អាណត្តិទៅឱ្យ B ដើម្បីទិញរថយន្តថ្មីពី C ដែលជាកាតព្វ កិច្ចរបស់ខ្លួន ហើយទទួលបានសិទ្ធិទាមទារឱ្យ C ប្រគល់រថយន្ត។ ប្រសិនបើគ្មានការព្រមព្រៀងពិសេស B ត្រូវ ប្រគល់រថយន្តនោះទៅឱ្យ A នៅក្នុងករណីដែលខ្លួនបានទទួលរថយន្តនោះរួចហើយ ឬ ក៏ផ្ទេរសិទ្ធិទាមទារឱ្យ C ប្រគល់រថយន្តនៅក្នុងករណីដែល គាត់មិនទាន់បានទទួលរថយន្តនោះនៅឡើយទេ។

### ២.២.២.៤. ការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតដែលបានប្រើប្រាក់

នៅក្នុងអំឡុងពេល ចាត់ចែងកិច្ចការអាណត្តិ បើអាណត្តិគាហកបានទទួលប្រាក់ពីតតិយជន ប្រាក់នោះ គឺជារបស់អាណត្តិទាយក ប៉ុន្តែប្រសិនបើអាណត្តិគាហកបានយកប្រាក់នោះទៅប្រើដើម្បីផលប្រយោជន៍របស់ ខ្លួន នោះគាត់ត្រូវបង់ការប្រាក់ ដោយគិតចាប់ពីថ្ងៃដែលបានប្រើប្រាក់នោះ។ មូលហេតុដែលអាណត្តិគាហកសង នៅការប្រាក់ពីព្រោះ ប្រាក់ដែលទទួលបានក្នុងអំឡុងពេលអាណត្តិ ជាកម្មសិទ្ធិរបស់អាត្តិទាយក។ មិនត្រឹមតែ សងនៅការប្រាក់នៃការយឺតយាងប៉ុណ្ណោះទេ គឺត្រូវសងនូវការខូចខាតផ្សេងៗទៀតនៅពេលដែលអាណត្តិគា ហកបានប្រើប្រាក់នោះ[58]។

ឧទាហរណ៍៖ អាណត្តិទាយក គាត់រំពឹងទុកថានឹងបានប្រាក់ពីការចាត់ចែងកិច្ចការអាណត្តិ ដើម្បីយក ទៅទិញនៅម៉ូតូមួយគ្រឿងដែលគាត់ស្រលាញ់ ប៉ុន្តែដោយសារប្រាក់នោះ អាណត្តិគាហកគាត់មិនបានប្រគល់ឱ្យ នោះទេ ដូច្នេះធ្វើឱ្យគាត់បាត់បងនូវផលប្រយោជន៍ ដែលគាត់ខំរំពឹងទុកថានឹងទទួលទិញម៉ូតូបានក្នុងតម្លៃ ថោក។ ដូច្នេះអាណត្តិគាហកត្រូវតែទទួលខុសត្រូវ។

### ២.២.២.៥. ករណីយកិច្ចសង្គ្រោះបន្ទាន់នៅក្រោយពេលបញ្ចប់អាណត្តិ

ជាទូទៅ ប្រសិនបើអាណត្តិត្រូវបានរំលាយ កាតព្វកិច្ច និងសិទ្ធិទាមទារទាំងអស់ត្រូវរលត់។ ប៉ុន្តែ វាមាន សារៈសំខាន់ក្នុងការការពារផលប្រយោជន៍របស់អាណត្តិទាយក ពីការរងការខូចខាត ដែលកើតឡើងដោយសារ

---

[57] មាត្រា៦៥៦ នៃក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ ១៩៩២

[58] មាត្រា ៦៥៣ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ហេតុការណាមួយ ដែលមិនអាចព្យាករណ៍បាន ក្នុងអំឡុងពេលនៃការបញ្ចប់អាណត្តិ រហូតដល់អាណត្តិទាយក ឬអ្នកផ្សេងទៀត អាចចាត់ចែងកិច្ចការទាំងអស់ ដែលត្រូវបានប្រគល់ទៅឱ្យអាណត្តិគាហក។

ឧទាហរណ៍៖ នៅក្នុងករណី មរណភាពរបស់អាណត្តិគាហក កិច្ចសន្យាអាណត្តិ ត្រូវបានបញ្ចប់[59]។ ប៉ុន្តែអាណត្តិទាយក អាចមានការលំបាកក្នុងការចាត់ចែងការងាររបស់ខ្លួន។ ដូច្នេះសន្តតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិគាហក ត្រូវធ្វើការចាត់ចែងកិច្ចការអាណត្តិនោះ រហូតដល់ពេលអាណត្តិទាយក សន្តតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិទាយក អាចចាត់ចែងកិច្ចការនោះបាន។

ទទឹមនឹងនេះដែរ ឧទាហរណ៍ **ក** បានផ្តល់អាណត្តិទៅឱ្យ **ខ** ដើម្បីប្រមូលបំណុលដែលជាប្រាក់ពី **គ** ហើយកិច្ចសន្យាត្រូវបានបញ្ចប់ គ្រាន់តែនៅមុនពេលនៃការបញ្ចប់នូវអាជ្ញាយុកាលនៃការរំលត់។ នៅក្នុងករណីនេះ ដោយផ្អែកទៅ លើមាត្រា ៦៥០ **ខ** ត្រូវចាត់វិធានការណ៍ ដើម្បីបញ្ចប់នូវអាជ្ញាយុកាលនៃការរំលត់ ដូចជាការទាមទារឱ្យសងជាប្រាក់ ការផ្អាកអាជ្ញាយុកាលនៃការរំលត់ជាអាទិ៍ ទោះជានៅក្រោយការបញ្ចប់អាណត្តិក៏ដោយ។

[59] មាត្រា៦៤៩ កថាខណ្ឌទី១ ចំណុច ក នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# ជំពូកទី ៣
# ការបញ្ចប់ និងអានុភាពនៃការបញ្ចប់កិច្ចសន្យាអាណត្តិ

## ផ្នែកទី ១ ការបញ្ចាប់កិច្ចសន្យាអាណត្តិ

មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ មាន២ប្រភេទគឺ ការបញ្ចប់ដោយ ការរំលាយ កិច្ចសន្យាអាណត្តិ និង ការបញ្ចប់ដោយមូលហេតុផ្សេងៗ។

### ១.១. ការរំលាយកិច្ចសន្យាអាណត្តិ

ជាគោលការណ៍ ប្រសិនបើកិច្ចសន្យារំលាយ អានុភាពនៃការរំលាយនោះ មានប្រតិសកម្ម ហើយកិច្ចសន្យានោះ ត្រូវចាត់ទុកថា គ្មានតាំងតែពីដំបូង។ ភាគីទាំងសងខាង ក៏ត្រូវរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យាដែរ។ ប្រសិនបើ កាតព្វកិច្ចត្រូវបានអនុវត្តរួចហើយ ភាគីដែលបានទទួល អនុវត្តកាតព្វកិច្ចនោះត្រូវធ្វើបដិទាន (សូមមើលមាត្រា ៤១១ នៃក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៧)។

តែចំពោះកិច្ចសន្យាអាណត្តិវិញ ភាគីនីមួយៗ អាចរំលាយកិច្ចសន្យាអាណត្តិ នៅពេលណាក៏បាន[60] ។ កិច្ចសន្យាអាណត្តិ គឺពឹងផ្អែកលើទំនាក់ទំនងនៃការទុកចិត្តគ្នារវាងគូភាគី ប៉ុន្តែ ប្រសិនបើភាគីណាម្ខាងបានបាត់បង់ការទុកចិត្តទៅលើភាគីម្ខាងទៀត នោះពួកគេមិនអាចថែរក្សាទំនាក់ទំនងនេះបានទៀតទេ។ ដូច្នេះ ក្រមរដ្ឋប្បវេណីបានចែងថា ភាគីនីមួយៗ អាចរំលាយកិច្ចសន្យាអាណត្តិបាន ដោយមិនចាំបាច់មានហេតុផលសមរម្យក៏បាន។

ក៏ប៉ុន្តែ ប្រសិនបើភាគីបានរំលាយអាណត្តិ នៅក្នុងអំឡុងពេលដែលធ្វើឱ្យខូចខាតដល់ភាគីម្ខាងទៀត ភាគីនោះត្រូវសងសំណងនៃការខូចខាតទៅភាគីម្ខាងទៀត[61] ។

ឧទាហរណ៍៖ ប្រសិនបើអាណត្តិគាហករំលាយកិច្ចសន្យាអាណត្តិ នៅពេលដែលអាណត្តិទាយកមិនអាចរកបានអាណត្តិគាហកថ្មីមួយទៀត នោះអាណត្តិគាហកត្រូវសងសំណងនៃការខូចខាតប្រសិនបើមានការខូចខាតនោះ។

ទោះបីជាមូលហេតុនៃការរំលាយ គឺជាមូលហេតុដែលមិនអាចជៀសវាងបាន ឧទាហរណ៍ ដូចជា នៅក្នុងករណីដែលអាណត្តិគាហកមានជំងឺ ហើយមិនអាចបន្តកិច្ចការអាណត្តិបាន នោះអាណត្តិគាហកមិនចាំបាច់សងសំណងនៃការខូចខាតទេ។

[60] មាត្រា៦៤៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[61] មាត្រា៦៤៥ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**១.២. ការបញ្ចប់ដោយមូលហេតុផ្សេងៗ**

ក្រៅពីកិច្ចសន្យាអាណត្តិត្រូវបានរំលាយ ដូចដែលមានចែងនៅក្នុងមាត្រា ៦៤៧ នៃក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ ២០០៧ ហើយកិច្ចសន្យាអាណត្តិក៏ត្រូវបានរំលាយដូចខាងក្រោម[62]៖

**ក.** ប្រសិនបើ អាណត្តិទាយក ឬ អាណត្តិគាហក បានទទួលមរណភាព។ នៅពេលដែល ភាគីណាមួយនៃកិច្ចសន្យាណត្តិ ដែលមានអាណត្តិទាយក ឬអាណត្តិគាហកបានទទួលមរណៈភាព នៅក្នុងពេលដែលកិច្ចសន្យាអាណត្តិកំពុងមានសុពលភាព ជាហេតុធ្វើឱ្យកិច្ចសន្យាអាណត្តិនោះ ត្រូវបានបញ្ចប់។

ឧទាហរណ៍៖ **ក** ជាអាណត្តិទាយក បានចុះកិច្ចសន្យាអាណត្តិជាមួយ **ខ** ជាអាណត្តិគាហក ខណៈកំពុងបន្តអនុវត្តអាណត្តិ នោះ **ខ** ក៏បានមានជំងឺធ្ងន់ធ្ងរបណ្ដាលឲ្យបាត់បង់ជីវិត ហេតុដូចនេះ ទោះបីជា **ក** មិនចង់រំលាយកិច្ចសន្យា ក៏កិច្ចសន្យានោះត្រូវតែទទួលនៃការរំលាយកិច្ចសន្យាអាណត្តិដែរ ដោយហេតុថា មរណៈភាពរបស់អាណត្តិគាហក។

**ខ.** ប្រសិនបើ អាណត្តិទាយក ឬអាណត្តិគាហក ត្រូវបានប្រកាសធនក្ស័យ។ ក្នុងចំណោម ភាគីទាំងពីរប្រសិនបើភាគីណាមួយត្រូវបានតុលាការប្រកាសថា ធនក្ស័យនោះ កិច្ចសន្យាអាណត្តិនោះនិងត្រូវបានបញ្ចប់ដែរ។

ឧទាហរណ៍៖ បុរស **ក** ជាអាណត្តិទាយក បានចុះកិច្ចសន្យាអាណត្តិជាមួយ បុរស **ខ** ខណៈដែលកិច្ចសន្យានោះនៅមានសុពលភាព ក្រុមហ៊ុនវិនិយោគរបស់អាណត្តិទាយក ត្រូវបានតុលាការប្រកាសអំពីធនក្ស័យ ហេតុដូចនេះ កិច្ចសន្យារវាងគេទាំងពីរខាងលើនេះក៏ត្រូវបញ្ចប់ផងដែរ ទៅតាមការប្រកាសរបស់តុលាការ។

**គ.** ការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ឬប្រកាសចាប់ផ្ដើមហិតូបត្ថម្ភទៅលើអាណត្តិទាយក ប្រសិនបើអាណត្តិទាយកត្រូវបានតុលាការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ឬប្រកាសចាប់ផ្ដើមហិតូប-ត្ថម ខណៈកិច្ចសន្យាអាណត្តិកំពុងមានសុពលភាពដែលត្រូវអនុវត្ត ដោយសារអាណត្តិទាយក ត្រូវបានបាត់បង់ ឬអសមត្ថភាពខាងបញ្ញាស្មារតី ពុំអាចវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់តទៅទៀតបាននោះ ដូច្នេះ សុពលភាពនៃកិច្ចសន្យាអាណត្តិនិងត្រូវបញ្ចប់ដូចគ្នាផងដែរ។

ឧទាហរណ៍៖ អាណត្តិទាយក **ក** បានចុះកិច្ចសន្យាអាណត្តិជាមួយអាណត្តិគាហក **ខ** បន្ទាប់ពីបានធ្វើនូវកិច្ចសន្យារួច **ក** បានជួបគ្រោះថ្នាក់ ហើយគ្រូពេទ្យបានបញ្ជាក់ថា **ក** ប៉ះពាល់ក្បាល ដែលធ្វើឲ្យគាត់បាត់បង់ភាពជាម្ចាស់ការលើខ្លួនឯង ដែលតម្រូវស្នើសុំអ្នកគ្រប់គ្រងគាត់ បន្ទាប់ពីតុលាការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភកៈរួច កិច្ចសន្យាអាណត្តិរវាង **ក** និង **ខ** ក៏ត្រូវបញ្ចប់ផងដែរ។

---

[62] សូមមើលមាត្រា៦៤៩ កថាខណ្ឌទី ១ ចំណុចទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ឃ.** ការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ឬប្រកាសចាប់ផ្ដើមហិតូបត្ថម្ភទៅលើអាណត្តិគាហក ចំណុចមួយនេះក៏មិនខុសគ្នាពីការបញ្ចប់កិច្ចសន្យាអាណត្តិ ដោយមូលហេតុនៃការចាប់ផ្ដើមប្រកាសអាណាព្យាបាលទូទៅ ឬការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភទៅលើអាណត្តិទាយកផងដែរ ប្រសិនបើអាណត្តិគាហកត្រូវបានប្រកាស នោះកិច្ចសន្យាអាណត្តិនឹងត្រូវបានបញ្ចប់។

**ង.** ចំពោះ នីតិបុគ្គលរវាងអាណត្តិទាយក ឬ អាណត្តិគាហក ដែលជានីតិបុគ្គលបានរលាយបាត់ នោះនាំឱ្យកិច្ចសន្យាអាណត្តិត្រូវបានបញ្ចាប់ ដោយហេតុ ថានីតិបុគ្គលដែលជាអាណត្តិទាយក ឬ អាណត្តិគាហកត្រូវរលាយអស់នៅបុគ្គលភាពគតិយុត្តហើយ។

**ច.** អាណត្តិទាយក ឬអាណត្តិគាហក ដែលជានីតិបុគ្គល ត្រូវបានរួមបញ្ចូលជាមួយនីតិបុគ្គលផ្សេងទៀត មានន័យថា ប្រសិនបើអាណត្តិទាយក ឬអាណត្តិគាហកដែលស្ថិតនៅក្នុងរូបភាពជានីតិបុគ្គល ហើយក្រុមហ៊ុននោះត្រូវបានរំលាយ ហើយទៅរួមបញ្ចូលជាមួយក្រុមហ៊ុននីតិបុគ្គលផ្សេងទៀតក៏ដោយ ក៏កិច្ចសន្យាអាណត្តិនោះត្រូវបានបញ្ចប់ផងដែរ។

**ឆ.** ប្រសិនបើមូលហេតុផ្សេងៗ ដែលបានកំណត់តាមការព្រមព្រៀង របស់ភាគីបានកើតឡើង។ ចំណុចនេះបង្ហាញថាគូភាគីនៃ កិច្ចសន្យាអាណត្តិ មានសិទ្ធិធ្វើការកំណត់អំពីមូលហេតុនៃការបញ្ចប់ នូវកិច្ចសន្យាអាណត្តិបាន ដោយសារការព្រមព្រៀងរបស់ខ្លួន នៅក្នុងកិច្ចសន្យាបាន ។ ព្រោះមូលហេតុនៃការបញ្ចប់នូវកិច្ចសន្យាអាណត្តិដែលបានរៀប រាប់ខាងលើនេះ មិនមានលក្ខណៈដាច់ខាតទេ ដូចនេះគូភាគីមានសេរីភាពពេញទីនៅក្នុងការជ្រើសរើសយកមូលហេតុណាមួយដែលភាគី បានព្រមព្រៀងផ្សេងពីករណីខាងលើនេះ មកធ្វើជាមូលហេតុនៃបញ្ចប់នូវកិច្ចសន្យាអាណត្តិបាននៅក្នុងកិច្ចសន្យារបស់ខ្លួនក៏បានដែរ តាមឆន្ទៈព្រមព្រៀងរបស់ខ្លួនបាន។

ក្រៅពីបញ្ចប់អាណត្តិ ចាប់ពីចំណុច **ក** ដល់ចំណុច **ច** ខាងលើ ក៏ភាគីអាចព្រមព្រៀងពីការដែលអាណត្តិមិនបញ្ចប់ដែរ[63]។ ដោយសារបញ្ញត្តិខាងលើនេះ មិនមែនជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ដូច្នេះ ភាគីអាចព្រមព្រៀងគ្នាផ្សេងបាន។ វាមានន័យថា ភាគីអាចសន្យាបានដែរថា ទោះបីជា មានមូលហេតុណាមួយ ក្នុងចំណោមមូលហេតុ ដែលមានកំណត់នៅមាត្រា ៦៤៩ ចំណុច ក ដល់ ចំណុច ច ដែលនាំឱ្យអាណត្តិត្រូវបានបញ្ចប់ក៏ដោយ ក៏អាណត្តិ មិនបញ្ចប់ដែរ។ លើសពីនេះ ភាគីអាចលើកយក មូលហេតុផ្សេង ក្រៅពីមូលហេតុ ដែលមានចែងក្នុងមាត្រា ៦៤៩ មកធ្វើជាមូលហេតុ នៃការមិនបញ្ចប់អាណត្តិបាន។

[63] មាត្រា៦៤៩ កថាខណ្ឌទី ២ ចំណុចទី ២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឧទាហរណ៍៖ **ឡុងឌី** (អាណត្តិទាយក) បានប្រគល់សិទ្ធិអំណាចរបស់ខ្លួន ឱ្យ **រក្សា** (អាណត្តិគាហក) ក្នុងការចាត់ចែងកិច្ចការ ឱ្យឃ្វាលក្របីឱ្យខ្លួន ហើយនៅក្នុងកិច្ចសន្យាពួកគេទាំងពីរ បានធ្វើការសន្យាថា បើ**ឡុងឌី** ស្លាប់ នោះកិច្ចសន្យាអាណត្តិមិនត្រូវបានរំលាយឡើយ។ ដូច្នេះទោះបីជា **រក្សា** ចង់រំលាយកិច្ចសន្យាដោយផ្អែកលើការស្លាប់របស់ **ឡុងឌី** គឺមិនអាចធ្វើទៅបានទេ។

លើសពីនេះទៅទៀត ភាគីក៏អាចយកហេតុផ្សេងទៀត ក្រៅពីមូលហេតុដែលបានកំណត់ចាប់ពី ចំណុច ក ដល់ចំណុច ច នេះមកបញ្ចូលនូវមូលហេតុនៃការបញ្ចប់អាណត្តិបានដែរ នៅក្នុងកិច្ចសន្យារបស់ខ្លួនបាន[64]។

ឧទាហរណ៍៖ **ដារ៉ា** (អាណត្តិទាយក) បានផ្តល់សិទ្ធិឱ្យ **វណ្ណដា** (អាណត្តិគាហក) ក្នុងការធ្វើសកម្មភាពក្នុងការមើលថែរក្សាឡានរបស់ខ្លួនរហូត ដល់ពេលដែលខ្លួនត្រឡប់មកពីអាមេរិកវិញ។ នៅពេលដែល **ដារ៉ា** ត្រឡប់មកវិញ គឺកិច្ចសន្យាត្រូវបានបញ្ចប់។

ទោះបីជាជាមានការលើកឡើងខាងលើថា ឱ្យតែមានការព្រមព្រៀងអំពីការមិនបញ្ចប់អាណត្តិក៏ដោយ ហើយទោះបីជាមូលហេតុ ដែលបានកំណត់ចាប់ពីចំណុច ក ដល់ ចំណុច ច បានកើតឡើងក៏ដោយ ក៏អាណត្តិមិនត្រូវបានបញ្ចប់ដែរ។

ប៉ុន្តែបញ្ញត្តិនេះ មិនយកអនុវត្តឡើយ ចំពោះមរណភាពរបស់អាណត្តិគាហក ការចាប់ផ្តើមអាណាព្យាបាលទូទៅ សម្រាប់អាណត្តិគាហក ឬការរំលាយ ឬការបញ្ចូលនៃអាណត្តិគាហកដែលជានីតិបុគ្គល[65]។ ក្នុងន័យនេះ ការព្រមព្រៀងណាផ្សេងពីចំណុចនេះ មិនអាចធ្វើទៅបានទេ។ ហេតុដូច្នេះ មរណភាព ការរំលាយ ឬ ការបញ្ចូលគ្នានៃអាណត្តិគាហក មិនត្រូវរាប់បញ្ចូលថា ជាមូលហេតុសម្រាប់ការព្រមព្រៀងផ្សេងទេ ដោយចាត់ទុកថាអាណត្តិត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ (ចំពោះញត្តិនេះ មិនរារាំងដល់នីតិបុគ្គលថ្មីដែលកើតឡើងក្រោយ ការរួមបញ្ចូលគ្នានៃនីតិបុគ្គល ចំពោះការបង្កើតនៃកិច្ចសន្យាអាណត្តិថ្មី ដើម្បីបន្តអាណត្តិតទៅទៀតទេ)[66]។

## ផ្នែកទី ២ អានុភាពនៃការបញ្ចប់កិច្ចសន្យា

### ២.១. ពុំមានអានុភាពប្រតិសកម្ម

មាត្រា ៦៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានចែងថា អានុភាពនៃការរំលាយនោះ កើតមានឡើងដោយឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ហើយមិនមានអានុភាពប្រតិសកម្ម ដូចកិច្ចសន្យាជាបន្តផ្សេងទៀតទេ។ មូលហេតុដែលការរំលាយអាណត្តិ មិនមានអានុភាព ប្រតិសកម្ម គឺថាទំនាក់ទំនងរវាងអាណត្តិទាយក អាណត្តិគាហក និង ភាគីម្ខាងទៀត អាចនឹងមានភាពស្មុគស្មាញ ប្រសិនបើ ការរំលាយមានអានុភាពប្រតិសកម្ម នៅក្នុង

[64] មាត្រា៦៤៩ វាក្យខណ្ឌទី ២ នៃសេចក្តីកំណត់ ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី
[65] មាត្រា៦៤៩ កថាខណ្ឌទី ២ ចំណុចទី ២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[66] មាត្រា៦៤៩ វាក្យខណ្ឌទី ៥ នៃសេចក្តីកំណត់ ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

ករណីនៃអាណត្តិ។ ដូច្នេះ នៅពេលកិច្ចសន្យាអាណត្តិ ត្រូវបានរំលាយ អាណត្តិគាហក ត្រូវប្រគល់ ឬ វត្ថុ ដែលខ្លួនបានទទួល ទាក់ទងនឹងការចាត់កិច្ចការអាណត្តិ ទៅឲ្យអាណត្តិទាយក ហើយ អាណត្តិទាយក ត្រូវបង់កម្រៃ ( នៅក្នុងករណីដែលមានការព្រមព្រៀងគ្នាពិសេស ) ឬ សោហ៊ុយចាំបាច់ ទៅឲ្យអាណត្តិគាហក តាមសមាមាត្រនៃភាគ ដែលបានអនុវត្តរួចហើយ។

**២.២. លក្ខខណ្ឌតតាំង**

លក្ខខណ្ឌតតាំងនៃការបញ្ចប់អាណត្តិ (មាត្រា ៦៥១ នៃក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ ២០០៧) មានគោលបំណង ដើម្បីការពារភាគីនៃកិច្ចសន្យាអាណត្តិ ដែលមិនដឹងអំពីការបញ្ចប់អាណត្តិពីការខូចខាត ដែលមិនអាចព្យាករណ៍បាន។ ដូច្នេះ ប្រសិនបើ ភាគីណាមួយ ដែលបានបញ្ចប់អាណត្តិ ដោយ មិនបានជូនដំណឹង ទៅភាគីម្ខាងទៀតនោះ នោះគាត់មិនអាចលើកយកមូលហេតុនៃការបញ្ចប់ អាណត្តិនេះ មកតតាំង ជាមួយនឹង ភាគីម្ខាងទៀត បានឡើយ។

ឧទាហរណ៍៖ **ក** បានផ្តល់អាណត្តិឱ្យ **ខ** ដើម្បីទិញរថយន្ត។ ក៏ប៉ុន្តែ **ក** ត្រូវបានប្រកាសធនក្ស័យ ប៉ុន្តែគាត់ មិនបានជូនដំណឹងអំពីហេតុការនេះទៅ **ខ** ទេ។ ក្រោយមក **ខ** ដែលមិនបានដឹងអំពីការបញ្ចប់អាណត្តិនេះ បានចុះកិច្ចសន្យាជាមួយ នឹង **គ** ។ នៅក្នុងករណីនេះ មិនអាចលើកឡើងអំពីការបញ្ចប់អាណត្តិបានទេ ហើយ កិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានអានុភាព ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ "កិច្ចសន្យាអាណត្តិ" នេះរួចមក អាចធ្វើការសន្និដ្ឋានបានថា ការជឿទុកចិត្តគ្នាគឺសំខាន់ណាស់ក្នុងការប្រាស្រ័យទាក់ទងគ្នា នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដែលអាចធ្វើឱ្យមនុស្សទាំងអស់ធ្វើការផ្តល់នូវសេវា ការពឹងពាក់គ្នា ឬការបង្កើតកិច្ចសន្យាដោយគ្មានការព្រួយបារម្ភណ៍។ ដោយសារតែមានការជឿទុកចិត្តគ្នាទៅវិញទៅមក និងការពឹងពាក់គ្នាបែបនេះហើយ ទើបបានជាមានច្បាប់កិច្ចសន្យាបានបង្កើតឡើងនៅតាមបណ្តាប្រទេសផ្សេងៗ ដើម្បីកំណត់ពីសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ដែលត្រូវអនុវត្តចំពោះគ្នាទៅវិញទៅមក។ ចំណែកនៅក្នុងប្រទេសកម្ពុជាក៏បានបង្កើតច្បាប់កិច្ចសន្យាដូចនៅប្រទេសដទៃដែរ ដើម្បីឱ្យគូភាគីបង្កើតកិច្ចសន្យាដោយគ្មានការភ័យខ្លាច។ ស្របជាមួយនឹងការជឿទុកចិត្តគ្នា ក៏បានបង្កើតនៅរបបមួយ ហៅថា ការតំណាង។ ភាគីដែលផ្តល់សិទ្ធិអំណាចឱ្យភាគីម្ខាងទៀតក្នុងការជួយចាត់ចែងកិច្ចការងារខ្លួន គេហៅថា អាណត្តិទាយក និងភាគីដែលព្រមជួយក្នុងកិច្ចការងារនេះហៅថា អាណត្តិគាហក ដែលពួកគេបានព្រមព្រៀងគ្នាបង្កើតនៅកិច្ចសន្យាមួយហៅថា កិច្ចសន្យាអាណត្តិ។ កិច្ចសន្យារវាងអាណត្តិទាយក និងអាណត្តិគាហក បានបង្កើតឡើងឱ្យមាននៅអានុភាពនៅពេលដែលពួកគេបានធ្វើការព្រមព្រៀងគ្នាដោយផ្ទាល់។ ក្រោយពីពួកគេបានបង្កើតនៅកិច្ចសន្យានេះឡើងនាំឱ្យសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេត្រូវបង្កើតឡើង ដែលត្រូវតែទទួលខុសត្រូវជាដាច់ខាត់។ ការជឿទុកចិត្ត និងភាពមានទំនាក់ទំនងល្អ នាំឱ្យការបង្កើតកិច្ចសន្យាអាណត្តិនេះ មិនយកកម្រៃ ឬយកកម្រៃ គឺអាស្រ័យលើអាណត្តិគាហក ថាយកកម្រៃឬមិនយក ហើយក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិពីបញ្ហានេះ ហើយដើម្បីគោរពទៅលើឆន្ទៈរបស់អាណត្តិគាហក ដោយផ្អែកលើគោលការណ៍ស្មគ្រ័ចិត្ត និងឈរលើមូលដ្ឋានជឿទុកចិត្តគ្នាទៅវិញទៅមក។

ដូច្នេះ អាណត្តិគាហក ត្រូវតែបំពេញកិច្ចការដោយយកចិត្តទុកដាក់ក្នុងឋានៈជាអ្នកជួយចាត់ចែងកិច្ចការដោយសុចរិត ត្រឹមត្រូវ និងដោយប្រុងប្រយ័ត្ន។ បន្ថែមពីលើនេះ អាណត្តិគាហកត្រូវតែរាយការណ៍អំពីសកម្មភាពនៃការចាត់ចែងកិច្ចការអាណត្តិ ជូនដល់អាណត្តិទាយក ហើយខ្លួនក៏មាន កាតព្វកិច្ចក្នុងការប្រគល់វត្ថុ និងប្រាក់ក្នុងអំឡុងពេលដែលចាត់ចែងកិច្ចការអាណត្តិ។ ជាពិសេស អាណត្តិគាហក ត្រូវតែទទួលខុសត្រូវនៅពេលដែលបញ្ចប់អាណត្តិ ទោះបីក្នុងករណីដែលខ្លួនទទួលមរណៈភាពក៏ដោយ ក៏សន្តតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវតែទទួលខុសត្រូវចំពោះកិច្ចការអាណត្តិនេះ រហូតដល់ពេលដែលអាណត្តិទាយករកអ្នកថ្មីមកជំនួសបាន។

ចំពោះ អាណត្តិទាយក ក៏មានករណីកិច្ចក្នុងការបង់កម្រៃ សោហ៊ុយ និងសំណងការខូចខាតជូនអាណត្តិគាហកដែលបានកើតឡើងក្នុងអំឡុងពេលនៃអាណត្តិ។ កិច្ចសន្យាអាណត្តិនឹងត្រូវបានបញ្ចប់ នៅពេលដែលគូភាគីព្រមព្រៀងគ្នាក្នុងការបញ្ចប់នៅពេលណាក៏បាន ដោយហេតុថាកិច្ចសន្យាអាណត្តិត្រូវបានបង្កើត

ឡើងដោយការព្រមព្រៀងគ្នា និងផ្អែកលើទំនាក់ទំនងនៃការទុកចិត្តគ្នារវាងគូភាគីទាំងសងខាង ហើយប្រសិនបើមានភាគីណាមួយបាត់បង់នៅការទុកចិត្តគ្នា នោះភាគីនោះអាចសុំរំលាយកិច្ចសន្យាអាណត្តិបាន។ ក្រៅពីការបញ្ចប់អាណត្តិ ដោយការព្រមព្រៀងរបស់គូភាគី ក៏អាណត្តិត្រូវបញ្ចប់ដោយស្វ័យប្រវត្តិដែរ នៅក្នុងករណីដែលនៅពេលដែលអាណត្តិគាហក ដែលជានីតិបុគ្គលត្រូវរំលាយ ឬត្រូវបានរំលាយចូលគ្នាក្លាយជានីតិបុគ្គលថ្មី និងក្នុងករណីដែលអាណត្តិទាយកត្រូវបានទួលមរណភាព។ នៅពេលដែលកិច្ចសន្យាអាណត្តិត្រូវបានរំលាយ បើភាគីណាមួយមិនបានជូនដំណឹងទៅភាគីម្ខាងទៀត នោះភាគីនោះមិនអាចលើកយកមូលហេតុនៃការបញ្ចប់អាណត្តិនេះ មកតតាំងជាមួយនឹងភាគីម្ខាងទៀតបានឡើយ។

សរុបសេចក្តីមក កិច្ចសន្យាអាណត្តិ ជាកិច្ចសន្យាដែលតម្រូវឱ្យគូភាគីនៃកិច្ចសន្យាត្រូវមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក ហើយត្រូវតែទទួលខុសត្រូវ នៅសកម្មភាពដែលខ្លួនបានធ្វើ ប្រសិនបើមានភាគីណាមួយនៃកិច្ចសន្យាបានធ្វើឱ្យខូចខាត គឺត្រូវតែទទួលខុសត្រូវចំពោះកំហុសរបស់ខ្លួន តាមរយៈការសងនូវសំណងការខូចខាត ទៅភាគីម្ខាងទៀត។

# អនុសាសន៍

ឆ្លងតាមការស្រាវជ្រាវ ទៅលើប្រធានបទ "**កិច្ចសន្យាអាណត្តិ**" យើងខ្ញុំសូមផ្តល់អនុសាសន៍ក្នុងន័យកែលំអរ ដើម្បីជាប្រយោជន៍នៃការអនុវត្តន៍កិច្ចសន្យា ឱ្យស្របទៅតាមអត្ថន័យនៃកិច្ចសន្យា ដែលគូភាគីបានកំណត់ដែលស្របទៅបញ្ញត្តិច្បាប់។

ជាដំបូង យើងខ្ញុំសូមផ្តល់អនុសាសន៍ ទៅលើនិយមន័យ នៃកិច្ចសន្យាអាណត្តិ នៅក្នុងនោះច្បាប់បានប្រើពាក្យ ប្រគល់សិទ្ធិអំណាចរបស់អាណត្តិទាយក ទៅឱ្យអាណត្តិគាហក ដើម្បីធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក។ ក្នុងន័យនេះ យើងមានការពិបាកយល់មិនដឹងជាច្បាប់តម្រូវឱ្យអាណត្តិគាហកធ្វើក្នុងនាមអាណត្តិទាយក ឬក្នុងនាមតំណាង ជាពិសេសមានការភាន់ច្រឡំទៅនឹងការតំណាង ដោយសារតែមានការស្រដៀងគ្នាខ្លាំងទៅនឹងការតំណាង ទាំងទ្រឹស្តី និងទាំងសកម្មភាព យើងពិតជាពិបាកធ្វើការបែងចែកឱ្យដាច់ណាថាសកម្មភាពណាជាសកម្មភាព អាណត្តិ ឬការតំណាងទេ។ ដោយសារនៅក្នុងការតំណាង ដែលគេធ្វើកិច្ចសន្យាគេតែងតែប្រើពាក្យ ប្រគល់សិទ្ធិឱ្យធ្វើការចាត់ចែង រីឯចំពោះអាណត្តិវិញគឺគេប្រើពាក្យប្រគល់សិទ្ធិអំណាចឱ្យដូចគ្នាដែរ ដូចដែលមានចែងនៅក្នុងនិយមន័យ នៃអាណត្តិ ដូច្នេះសុំបញ្ញត្តិឱ្យច្បាស់ៗមក ថាប្រគល់សិទ្ធិក្នុងន័យ អាណត្តិមានលក្ខណៈបែបណា និងប្រគល់សិទ្ធិក្នុងការតំណាងមានលក្ខណៈបែបណា។

ចំពោះសិទ្ធិ និងកាតព្វកិច្ចរបស់អាណត្តិទាយក ចែងមកមានការពិបាកយល់ដោយសារតែមានចែងនៅក្នុងបញ្ញត្តិតែមួយ។ ចំពោះសិទ្ធិ និងកាតព្វកិច្ចរបស់អាណត្តិគាហក គឺមានច្រើនជាងអាណត្តិទាយក ដូច្នេះពិតជាមិនសមសោះចំពោះគាត់ ជាពិសេសចំពោះអាណត្តិមិនយកកម្រៃ ដោយហេតុថាកិច្ចសន្យាអាណត្តិកើតចេញពីការជឿទុកចិត្តគ្នា ដូច្នេះបើឱ្យអាណត្តិគាហកឆ្លើយថាយកកម្រៃគឺពិតជាពិបាកណាក្នុងការឆ្លើយបែបនេះ ព្រោះពេលខ្លះអាចធ្វើឱ្យបាត់បង់ទំនងទំនងល្អរវាងពួកគេ។ ដូច្នេះអាណត្តិគួរតែបញ្ញត្តិថាយកកម្រៃ ពីព្រោះដើម្បីការ-ពារអាណត្តិគាហក និងដើម្បីជៀសវាងមានវិវាទេ នៅពេលដែលអាណត្តិបានធ្វើយកកម្រៃដោយមានការព្រម-ព្រៀងគ្នាមិនជាក់លាក់ និងដោយតុណ្ហីភាព។

ជាចុងក្រោយសុំបញ្ញត្តិពន្យល់ឱ្យបានច្បាស់ថា តើសកម្មភាពបែបណាជាកិច្ចសន្យាអាណត្តិ និងសកម្មភាពបែបណាជាការតំណាង ថ្វីត្បិតតែមានការបញ្ញត្តិផ្សេងគ្នាក៏ពិតមែន ក៏យើងនូវតែចែកមិនដាច់ដែររវាងកិច្ចសន្យាទាំងពីរនេះ។

# ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
- សេចក្តីកំណត់ ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៩ - ២០១០
- ក្រមរដ្ឋប្បវេណី ភាគ ១ ដល់ ៦ ឆ្នាំ ២០១២
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ១ - ២ ឆ្នាំ ២០១៣
- ច្បាប់រដ្ឋប្បវេណី (ករណីប្រទេសជប៉ុន) និពន្ធដោយ អ៊ីកិដា ម៉ាសាអូ
- ក្រមរដ្ឋប្បវេណីបារាំងឆ្នាំ ១៨៨៩
- ក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ ១៩៩៧
- ច្បាប់ស្តីពី កម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស ២៤ ឧសភា ២០១០
- សៀវភៅកិច្ចសន្យាពិសេស ភាគ ២ សាស្ត្រាចារ្យ អៀង សំណាង
- សៀវភៅ នីតិកាតព្វកិច្ច និងកិច្ចសន្យា សាស្ត្រាចារ្យ ហេង បូរ៉ា ឆ្នាំ ២០១៥ - ២០១៦ ។